សន្និសីទ
គោលនយោបាយអប់រំ៤

4th The Education Policy Conference







# ការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បី កសាងភាពធន់ និងធានាគុណភាពអប់រំ

# Towards Future-Ready Schools

## Building Resilience and Ensuring Quality

នាយកដ្ឋានគោលនយោបាយ
វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI)

# ក្រសួងអប់រំ យុវជន និងកីឡា

នាយកដ្ឋានគោលនយោបាយ នៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI)

# សន្និសីទគោលនយោបាយអប់រំលើកទី៤
# ស្តីពី
# ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគត
# ដើម្បីកសាងភាពធន់ និងធានាគុណភាពអប់រំ

ថ្ងៃពុធ ១១កើត ដល់ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
វិទ្យាស្ថានជាតិអប់រំ និងតាមកម្មវិធី Zoom ថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០២៤

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. គោលបំណងនៃសន្និសីទ ........ 2

៣. លទ្ធផលរំពឹងទុកនៃសន្និសីទ ........ 2

៤. របនាសម្ព័ន្ធនៃសន្និសីទ ........ 3

៥.សេចក្តីណែនាំសម្រាប់វាគ្មិន និងអ្នកសម្របសម្រួល ........ 3

៦. កម្មវិធីនៃសន្និសីទគោលនយោបាយអប់រំ លើកទី៤ ........ 12

៧. សមាសភាពចូលរួម ........ 14

៨. សុន្ទរកថាបើកកម្មវិធី ........ 15

៩. ខ្លឹមសារសំខាន់ៗនៃវេទិកាពិភាក្សា ........ 23

វេទិកាពិភាក្សាទី១៖ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀនល្អ ដើម្បីលើកកម្ពស់លទ្ធផលសិក្សា ... 23

វេទិកាពិភាក្សាទី២៖ ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ តាមរយៈការបង្វឹក និងប្រឹក្សាយោបល់ ........ 23

វេទិកាពិភាក្សាទី៣៖ តើបច្ចេកវិទ្យាជួយកាត់បន្ថយ ឬបង្កើនគម្លាត? តើយើងត្រូវធ្វើដូចម្តេចដើម្បី ប្រើប្រាស់បច្ចេកវិទ្យា ឱ្យបានប្រសើរជាងមុនដើម្បីលើកកម្ពស់ការសិក្សា? ........ 24

វេទិកាពិភាក្សាទី៤៖ ឧត្តមានុវត្តន៍ភាពជាដៃគូរវាងសាធារណៈ និងសហគមន៍ ........ 26

១០.អនុសាសន៍ និងមតិបិទសន្និសីទគោលនយោបាយអប់រំ លើកទី៤ ........ 26

១១.គោលនយោបាយគន្លឹះ ........ 29

១២.ឧបសម្ព័ន្ធ ........ 29

១២.១.ឧបសម្ព័ន្ធទី១៖ លិខិតស្នើសុំចាត់សមាសភាពចូលរួមសន្និសីទគោលនយោបាយអប់រំ លើកទី៤... 30

១២.២.ឧបសម្ព័ន្ធទី២៖លិខិតអញ្ជើញវាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល ........ 41

១២.៣.ឧបសម្ព័ន្ធទី៣៖តារាងស្នើសុំវាគ្មិន និងអ្នកសម្របសម្រួលតាមវេទិកាពិភាក្សានីមួយៗ ........ 57

១២.៤.ឧបសម្ព័ន្ធទី៤៖សំណើសមាសភាពចូលរួមតាមអង្គភាព និងស្ថាប័ននានា ........ 58

១២.៥.ឧបសម្ព័ន្ធទី៥៖ ឯកសារទស្សនាទាននៃសន្និសីទគោលនយោបាយអប់រំ លើកទី៤ ........ 63

១២.៦.ឧបសម្ព័ន្ធទី ៦៖ ការរចនា នានានៃសន្និសីទគោលនយោបាយអប់រំ លើកទី៤ ........ 68

# អារម្ភកថា

ក្នុងឆ្នាំ២០២៤ នាយកដ្ឋានគោលនយោបាយ (DoPo) និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានសហការគ្នារៀបចំសន្និសីទគោលនយោបាយអប់រំលើកទី៤ ស្តីពី « **ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និងធានាគុណភាពអប់រំ**» នៅវិទ្យាស្ថានជាតិអប់រំ និងតាមប្រព័ន្ធវីដេអូហ្សូម (Zoom Video Conference) ឯកក្រោមអធិបតីភាព ឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយផ្តោតទៅលើវេទិកាពិភាក្សាចំនួន៤៖

**វេទិកាពិភាក្សាទី១៖** ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀនល្អ ដើម្បីលើកកម្ពស់លទ្ធផលសិក្សា

**វេទិកាពិភាក្សាទី២៖** ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ តាមរយៈការបង្វឹក និងប្រឹក្សាយោបល់

**វេទិកាពិភាក្សាទី៣៖** តើបច្ចេកវិទ្យាជួយកាត់បន្ថយ ឬបង្កើនគម្លាត? តើយើងត្រូវធ្វើដូចម្តេចដើម្បីប្រើប្រាស់បច្ចេកវិទ្យាឱ្យបានប្រសើរជាងមុនដើម្បីលើកកម្ពស់ការសិក្សា?

**វេទិកាពិភាក្សាទី៤៖** ឧត្តមានុវត្តន៍ភាពជាដៃគូរវាងសាធារណៈ និងសហគមន៍

និងមានការចូលរួមពីអ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្តគោលនយោបាយគ្រប់លំដាប់ថ្នាក់រួមមានថ្នាក់ដឹកនាំក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនគ្រប់ភូមិសិក្សា មន្ទីរអយក.រាជធានី ខេត្ត ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន។

របាយការណ៍ដំណើរការនៃសន្និសីទគោលនយោបាយអប់រំលើកទី៤នេះ រៀបចំឡើងដោយផ្តោតលើចំណុចសំខាន់ៗដូចជា (១)ការរៀបចំមុនពេលសន្និសីទ (២) លទ្ធផលតាមវេទិកាពិភាក្សាទាំង៤ នៃសន្និសីទ និង (៣)ឧបសម្ព័ន្ធនៃសន្និសីទ។

យើងខ្ញុំសង្ឃឹមជឿជាក់យ៉ាងមុតមាំថា លទ្ធផលសន្និសីទគោលនយោបាយអប់រំនេះនឹងផ្តល់ធាតុចូលជាច្រើនដើម្បីរួមចំណែកក្នុងការសម្រេចបាននូវគោលដៅនៃការអប់រំនាពេលអនាគត តាមរយៈការបង្កើតវេទិកាពិភាក្សាដោយបើកចំហលើបញ្ហាប្រឈមនិងដំណោះស្រាយក្នុងវិស័យអប់រំ។

នាយកដ្ឋានគោលនយោបាយ សូមសម្តែងការកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ វាគ្មិនកិត្តិយស អ្នកសម្របសម្រួល ក្រុមការងារបច្ចេកទេស អ្នកពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍទាំងអស់ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ កម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញាដើម្បីរៀបចំសន្និសីទគោលនយោបាយអប់រំនេះឡើងប្រកបដោយជោគជ័យ។

ថ្ងៃ ចន្ទ ១១ កើត ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០២៤

**ប្រធានគណៈគ្រប់គ្រង**

Kanha

សាស្ត្រាចារ្យបណ្ឌិត **ឃុំ ចន្ទគន្ធលិកា**

# ១. សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) សហការជាមួយនឹងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានរៀបចំសន្និសីទគោលនយោបាយអប់រំប្រចាំឆ្នាំចំនួន៣លើករួចមកហើយ។ សន្និសីទឆ្នាំនេះជាលើកទី៤ ផ្តោតលើប្រធានបទស្តីពី **"ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និងធានាគុណភាពអប់រំ"**។ ព្រឹត្តិការណ៍ប្រមូលផ្តុំធនធានមនុស្សនេះមានសារៈសំខាន់ណាស់សម្រាប់គ្រប់ភាគីពាក់ព័ន្ធក្នុងការគិតគូរពិចារណានិងពិភាក្សាលើបញ្ហាសំខាន់ៗដែលបានកំណត់នូវចារិកលក្ខណៈនៃប្រព័ន្ធអប់រំនៅកម្ពុជា ។ ស្ថិតក្នុងបរិបទនៃសតវត្សរ៍ទី ២១ ដែលមានសុំាញ៉ាំ វាជាភារកិច្ចដ៏សំខាន់ដែលយើងត្រូវប្រកាន់យកនូវយុទ្ធសាស្ត្រអប់រំដែលមានគោលដៅបំពាក់បំប៉នសិស្សានុសិស្សនូវជំនាញដែលចាំបាច់ និងសមត្ថភាពគ្រប់គ្រាន់ដើម្បីត្រៀមទទួលជោគជ័យក្នុងបរិបទសកលលោកដែលមានការវិវត្តន៍ឥតឈប់ឈរ ។

ក្នុងឆ្នាំ ២០២៣ ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់អស់ពីសមត្ថភាពក្នុងការកសាងនិងប្រើប្រាស់នូវយុទ្ធសាស្ត្រថ្មីៗក្នុងគោលដៅធ្វើបរិវត្តកម្មសាលារៀនឱ្យក្លាយទៅជាសាលារៀនគំរូ។ គំនិតផ្តួចផ្តើមនេះមានគោលបំណងលើកកម្ពស់នូវគុណភាពនៃការបង្រៀននិងរៀន តាមរយៈការបង្កើតនូវឧទាហរណ៍ជាគំរូដែលដើរតួយ៉ាងសំខាន់សម្រាប់វាស់វែងនិងប្រៀបធៀប ដែលសាលារៀនានាអាចយកជាគំរូបាន។ យុទ្ធសាស្ត្រស្នូលនៃស្តង់ដាសាលារៀនគំរូចំនួន ៥ រួមមាន៖ ១.លទ្ធផលសិក្សារបស់សិស្ស ២.ការរៀននិងបង្រៀន ៣.ការចូលរួមរបស់សហគមន៍ ៤.ប្រតិបត្តិការនិងរដ្ឋបាលសាលារៀន និង ៥.គណនេយ្យភាពរបស់សាលារៀន ។

លើសពីនេះទៅទៀត ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការធ្វើបរិវត្តកម្មនៃប្រព័ន្ធអប់រំតាមរយៈការអប់រំឌីជីថលដែលជាមធ្យោបាយមួយក្នុងការលើកកម្ពស់នូវលទ្ធផលសិក្សារបស់សិស្ស និងការគ្រប់គ្រងតាមសាលារៀន ។ ដោយយល់ដឹងអំពីសក្តានុពលដ៏ធំធេងនៃបច្ចេកវិទ្យាក្នុងបរិវត្តកម្មវិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការវិនិយោគយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះ បណ្តាលគ្រូបង្រៀន និងធនធានឌីជីថល ។ គំនិតផ្តួចផ្តើមសំខាន់ៗក្នុងចំណោមគំនិតផ្តួចផ្តើមខាងលើនេះគឺមានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងសាលារៀន (SIS) ផងដែរ។ ដោយទាញយកអត្ថប្រយោជន៍ពីសក្តានុពលនៃសម្ភារៈ និងមធ្យោបាយឌីជីថលនានា ក្រសួងអប់រំ យុវជន និងកីឡាមានគោលដៅបង្កើតនូវបរិស្ថានរៀនសូត្រប្រកបដោយថាមពលនិងមានការចូលរួមខ្ពស់ដើម្បីបំពេញនូវសេចក្តីត្រូវការគ្រប់បែបយ៉ាងរបស់សិស្ស។

បន្ថែមពីនេះទៀត ក្រសួងក៏បានផ្តោតសំខាន់លើការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព និងការចូលរួមរបស់សហគមន៍ក្នុងការជំរុញឆ្ពោះទៅមុខនូវឧត្តមភាពនៃប្រព័ន្ធអប់រំ និងគណនេយ្យភាពរបស់សាលារៀន។ ការណ៍នេះត្រូវបានសម្តែងចេញតាមរយៈ ការបង្កើតនូវគណៈកម្មការគ្រប់គ្រងសាលារៀនក្នុងគោលដៅពង្រឹងនូវការចូលរួមរបស់សហគមន៍ និងលើកកម្ពស់នូវការធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតសាលារៀន។ រាជរដ្ឋាភិបាលកម្ពុជាក៏បានយកចិត្តទុកដាក់និងខិតខំប្រឹងប្រែងផងដែរក្នុងការផ្តល់អំណាចដល់ថ្នាក់ដឹកនាំសាលារៀន និងអ្នកពាក់ព័ន្ធនានាក្នុងការបំពេញមុខងារយ៉ាងសកម្មក្នុងកិច្ចការអភិបាលកិច្ចលើសាលារៀន និងដំណើរការរៀនសូត្រ ។ ដោយពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងសាលារៀននិងសហគមន៍ ក្រសួងអប់រំមានគោលដៅបង្កើតនូវបរិស្ថានសិក្សាដែលគាំទ្រដល់ការសិក្សាក៏ដូចជាសុខមាលភាពរបស់សិស្សានុសិស្ស ។

សន្និសីទគោលនយោបាយអប់រំនេះនឹងប្រមូលផ្ដុំគ្រប់ភាគីអ្នកពាក់ព័ន្ធមកពីមជ្ឈដ្ឋាននានានៅទូទាំងប្រទេសកម្ពុជាដែលក្នុងនោះរួមមាន អ្នកតាក់តែងគោលនយោបាយ ប្រតិបត្តិករ អ្នកអនុវត្តគោលនយោបាយសភាចារ្យ តំណាងនៃដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រូបង្រៀន និងសិស្សានុសិស្ស ។ កិច្ចពិភាក្សាក្នុងសន្និសីទនេះនឹងផ្ដោតទៅលើអាទិភាពជាគន្លឹះដែលមានគោលដៅលើកកម្ពស់ការរៀននិងបង្រៀននៅក្នុងប្រទេសកម្ពុជា ។ ចំណុចអាទិភាពទាំងនេះរួមមាន កំណែទម្រង់សាលារៀនគំរូ ការធ្វើសមាហរណកម្មនៃបច្ចេកវិទ្យាវិស័យអប់រំ ( Edtech ) សម្រាប់ការបង្រៀននិងរៀន ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលា និងភាពជាដៃគូរវាងសហគមន៍និងវិស័យសាធារណៈ ។

## ២. គោលបំណងនៃសន្និសីទ

សន្និសីទគោលនយោបាយអប់រំនេះមានគោលបំណងធំៗចំនួន ៣ គឺ៖

- ពិនិត្យឡើងវិញនូវវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងកំណែទម្រង់សាលារៀន ការចូលរួមរបស់សហគមន៍ និងការអភិវឌ្ឍវិជ្ជាជីវៈដល់គ្រូបង្រៀនដែលមានគោលដៅពង្រឹងនូវលទ្ធផលសិក្សារបស់សិស្ស
- ការរិះរកនូវនវានុវត្តភាពក្នុងវិស័យអប់រំតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាដែលអាចជួយដោះស្រាយបញ្ហាប្រឈមបច្ចុប្បន្ននិងវាយតម្លៃមើលថាតើបច្ចេកវិទ្យាអាចជួយលើកកម្ពស់ដល់ភាពធន់ក្នុងវិស័យអប់រំយ៉ាងដូចម្ដេច និងកំណត់នូវឧត្តមានុវត្តក៏ដូចជាបទពិសោធ ជោគជ័យនៃការធ្វើសមាហរណកម្មនូវបច្ចេកវិទ្យាក្នុងវិស័យអប់រំ
- សម្របសម្រួលនូវកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងរាជរដ្ឋាភិបាលជាមួយនឹងអ្នកពាក់ព័ន្ធផ្ទាល់ក្នុងវិស័យអប់រំ និងកំណត់នូវផ្នែលដែលមានសក្ដានុពលផ្ដល់នូវប្រយោជន៍ទៅវិញទៅមក និងប្រធានបទស្រាវជ្រាវដែលមានសក្ដានុពលដើម្បីរួមចំណែកក្នុងការលើកកម្ពស់នូវការតាក់តែងគោលនយោបាយផ្អែកលើភស្តុតាងក៏ដូចជាលើកកម្ពស់នូវគុណភាពនៃការស្រាវជ្រាវក្នុងវិស័យអប់រំក្នុងប្រទេសកម្ពុជា ។

## ៣. លទ្ធផលរំពឹងទុកនៃសន្និសីទ

- សេចក្ដីសង្ខេបគោលនយោបាយ ( នឹងត្រូវបោះពុម្ពដោយក្រសួងអប់រំ ឬ CDRI )
- របាយការណ៍សន្និសីទ
- របៀបវារៈនៃកិច្ចសហប្រតិបត្តិការស្រាវជ្រាវរួមគ្នាក្នុងពេលអនាគត

## ៤. រចនាសម្ព័ន្ធនៃសន្និសីទ

ដើម្បីទទួលបាននូវធាតុចូល និងគំនិតថ្មីៗនិងគ្រប់ជ្រុងជ្រោយ សន្និសីទគោលនយោបាយអប់រំលើកទី៤ នេះ ត្រូវបានចែកចេញជាវេទិកាពិភាក្សាចំនួន ៤ រួមមាន៖

**វេទិកាពិភាក្សាទី១៖** ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀនល្អ ដើម្បីលើកកម្ពស់លទ្ធផលសិក្សា

**វេទិកាពិភាក្សាទី២៖** ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ តាមរយៈការបង្វឹក និងប្រឹក្សាយោបល់

**វេទិកាពិភាក្សាទី៣៖** តើបច្ចេកវិទ្យាជួយកាត់បន្ថយ ឬបង្កើនគម្លាត? តើយើងត្រូវធ្វើដូចម្តេចដើម្បីប្រើប្រាស់បច្ចេកវិទ្យាឱ្យបានប្រសើរជាងមុនដើម្បីលើកកម្ពស់ការសិក្សា?

**វេទិកាពិភាក្សាទី៤៖** ឧត្តមានុវត្តន៍ភាពជាដៃគូរវាងសាធារណៈ និងសហគមន៍

វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល ព្រមទាំងអ្នកចូលរួមមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនគ្រប់ភូមិសិក្សា ដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល នឹងចែករំលែកការអនុវត្តជាក់ស្តែង ឧត្តមានុវត្តន៍ ដែលទាក់ទងនឹងប្រធានបទនៃវេទិកាពិភាក្សានីមួយៗ។

នាយកដ្ឋានគោលនយោបាយ និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ទទួលខុសត្រូវរួមគ្នាលើការរៀបចំសន្និសីទគោលនយោបាយអប់រំលើកទី៤នេះ ទាំងបច្ចេកទេស និងការងាររដ្ឋបាល ដូចជា កំណត់ប្រធានបទសន្និសីទ រៀបចំឯកសារទស្សនាទាន កំណត់វេទិកាពិភាក្សា ព្រមទាំងរៀបចំសេចក្តីណែនាំសម្រាប់វាគ្មិននិងអ្នកសម្របសម្រួល កំណត់សមាសភាពចូលរួម និងផ្តល់នូវរបកគំហើញនៃការស្រាវជ្រាវនានា ដើម្បីរួមចំណែកគាំទ្រដល់វេទិកាពិភាក្សានីមួយៗជាដើម។

## ៥.សេចក្តីណែនាំសម្រាប់វាគ្មិន និងអ្នកសម្របសម្រួល

ក្រុមការងាររៀបចំសន្និសីទគោលនយោបាយអប់រំលើកទី៤ មានសេចក្តីសោមនស្សរីករាយដែលឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា បានយល់ព្រមធ្វើជាអ្នកសម្របសម្រួល និង ជាវាគ្មិនក្នុងសន្និសីទគោលនយោបាយអប់រំលើកទី៤ ស្តីពី "**ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់និងធានាគុណភាពអប់រំ** " ។ សេចក្តីណែនាំនេះ មានគោលបំណងធ្វើឱ្យវេទិកាពិភាក្សារួមគ្នាមានលទ្ធផលជាផ្លែផ្កា និងមានលក្ខណៈអន្តរកម្មខ្ពស់បំផុតតាមតែអាចធ្វើទៅបាន ជាពិសេស គឺផ្តោតទៅលើវគ្គពិភាក្សា និង សំណួរចម្លើយ។ ពេលវេលាសរុបសម្រាប់វេទិកាពិភាក្សានីមួយៗ មានរយៈពេល៩០ នាទី ។ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកសម្របសម្រួល និងវាគ្មិនក្នុងវេទិកាទាំង៤ យើងខ្ញុំសូមផ្តល់ជូននូវសេចក្តីណែនាំខ្លីៗលើដំណើរការនៃកិច្ចពិភាក្សាដូចខាងក្រោម៖

| ល.រ | សកម្មភាព | ពេលវេលា |
|---|---|---|
| ១ | ការណែនាំប្រធានបទ និងវាគ្មិន | ១០ នាទី |
| ២ | កិច្ចពិភាក្សា | ៤០ នាទី |
| ៣ | សំណួរ និងចម្លើយពីអ្នកចូលរួម (បើកចំហ) | ៣០ នាទី |
| ៤ | មតិគន្លឹះ និងការកត់សម្គាល់របស់វាគ្មិន | ៥ នាទី |
| ៥ | សរុបសេចក្តី និងសង្ខេបដោយអ្នកសម្របសម្រួល | ៥ នាទី |
| **ពេលវេលាសរុប** | | ៩០ នាទី |

**ដំណើរការនៃកិច្ចពិភាក្សា**

១.នៅកិច្ចចាប់ផ្តើមនៃកិច្ចពិភាក្សានីមួយៗ អ្នកសម្របសម្រួល នឹងធ្វើការណែនាំជាសង្ខេបលើប្រធានបទពិភាក្សា និងណែនាំអំពីវាគ្មិន។ សេចក្តីផ្តើមនេះ អាចមានរយៈពេលប្រហែល ១០ នាទី ។

២.ជំហានបន្ទាប់ គឺជាវគ្គពិភាក្សាដែលមានរយៈពេល ៤០ នាទី សម្រាប់វេទិកាពិភាក្សានីមួយៗ អ្នកសម្របសម្រួលនឹងសួរជាសំណួរបើកមុខដែលមានលក្ខណៈទូលំទូលាយទៅកាន់វាគ្មិននីមួយៗ ឱ្យធ្វើការបកស្រាយដោយយោងទៅតាមទស្សនៈ និងជំនាញរបស់ខ្លួន។ បន្ទាប់ពីវាគ្មិនបានផ្តល់នូវមតិ ឬ ចំណាប់អារម្មណ៍ អ្នកសម្របសម្រួលអាចសួរសំណួរបន្ថែមទៅកាន់វាគ្មិនណាម្នាក់ ដើម្បីទទួលបានព័ត៌មានបន្ថែម និងជំរុញនូវវេទិកាកិច្ចពិភាក្សានោះ។

៣. ក្រោយកិច្ចពិភាក្សា អ្នកសម្របសម្រួល នឹងបើកចំហវេទិកាសម្រាប់សំណួរពីអ្នកចូលរួម ដែលមានរយៈពេល៣០ នាទី សម្រាប់វេទិកាពិភាក្សានីមួយៗ អ្នកសម្របសម្រួល ត្រូវប្រាប់អ្នកចូលរួមដែលចង់សួរជាសំណួរឱ្យធ្វើការណែនាំខ្លួនដោយគ្រាន់តែប្រាប់ឈ្មោះ និងស្ថាប័នដែលខ្លួនធ្វើការ មុននឹងធ្វើការចោទជាសំណួរ ។ អ្នកចោទជាសំណួរ ត្រូវបានលើកទឹកចិត្តឱ្យសួរសំណួរឱ្យបានច្រើន ប៉ុន្តែប្រយោគសំណួរត្រូវតែខ្លី និងខ្លឹមជាជាងសួរជាប្រយោគវែង ដើម្បីបង្កើនឱកាសសួរសំណួររបស់អ្នកចូលរួមដទៃទៀត។

**ចំណាំ៖** ចំពោះអ្នកចូលរួមផ្ទាល់អាចលើកដៃសួរសំណួរបាន នោះក្រុមការងារនឹងផ្តល់ម៉ៃក្រូហ្វូនជូន។ ចំពោះអ្នកចូលរួមតាមរយៈកម្មវិធីហ្ស៊ូម ពួកគេអាចចុចសញ្ញាលើកដៃ រួចសួរតាមរយៈការបើកឧបករណ៍បំពងសម្លេងក្នុងវីដេអូហ្ស៊ូមរបស់ខ្លួនរួចសួរសំណួរដោយផ្ទាល់មាត់ ឬអាចសរសេរជាសំណួរហើយទម្លាក់មកក្នុងប្រអប់សាររបស់កម្មវិធីវីដេអូហ្ស៊ូម ឬអាចសួរតាមរយៈស្លាយដូ(Slido)ដែលក្រុមការងាររៀបចំជាតំណភ្ជាប់ជូន។ ចំពោះអ្នកទស្សនាការផ្សាយផ្ទាល់តាមគេហទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏អាចផ្តល់មតិក្នុងហ្វេសប៊ុកបានដែរ។ ចំពោះសំណួរដែលត្រូវបានសួរដោយ

អ្នកចូលរួមតាមហ្វេសប៊ុក និងប្រអប់សាររបស់ហ្សូម ក្រុមការងារនៃគណៈកម្មការរៀបចំវេទិកានឹងបញ្ជូនទៅកាន់អ្នកសម្របសម្រួលវេទិកាពិភាក្សា។

៤.នៅចុងបញ្ចប់នៃកិច្ចពិភាក្សា អ្នកសម្របសម្រួល នឹងអញ្ជើញវាគ្មិនទាំងអស់ឱ្យផ្តល់នូវមតិសន្និដ្ឋានសង្ខេប (មតិគន្លឹះ) ឬផ្តល់នូវការបកស្រាយឱ្យច្បាស់លាស់បន្ថែមទៀត ព្រមទាំងចែករំលែកនូវ ទស្សនៈផ្ទាល់របស់ពួកគាត់ក្នុងរយៈពេល ៥ នាទី ។ បន្ទាប់មក អ្នកសម្របសម្រួលនឹងថ្លែងអំណរគុណដល់វាគ្មិន ធ្វើសេចក្តីសង្ខេបជាចុងក្រោយទៅលើកិច្ចពិភាក្សាទាំងមូលក្នុងរយៈពេល ៥ នាទីទៀត ។

ខាងក្រោមនេះ គឺជាសំណួរនាំមុខ សម្រាប់អ្នកសម្របសម្រួលនៃវេទិកាពិភាក្សាទាំង៤។ អ្នកសម្របសម្រួលគួររៀបចំផងដែរនូវសំណួរបន្ថែមទៀត ដោយសំណួរនេះមានមូលដ្ឋានលើកិច្ចប្រជុំត្រៀមរវាងអ្នកសម្របសម្រួល និងវាគ្មិនទាំងអស់។ គណៈកម្មការរៀបចំកម្មវិធី នឹងរៀបចំកិច្ចប្រជុំមុនដំណើរការវេទិកាពិភាក្សានៅថ្ងៃទី២០ ខែមីនា ឆ្នាំ ២០២៤ ដើម្បីពិភាក្សាអំពីដំណើរការនៃវេទិកាពិភាក្សានីមួយៗ។

**ចំណាំ៖** ក្រុមការងាររៀបចំសន្និសីទសូមស្នើសុំអ្នកទទួលបន្ទុកតាមវេទិកាពិភាក្សានីមួយៗ ដើម្បីប្រមូលជីវប្រវត្តិសង្ខេប (Brief Bio) របស់វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល (មានទម្រង់ផ្តល់ជូនដោយក្រុមការងាររៀបចំសន្និសីទ) ដោយភ្ជាប់ជាមួយរូបថតមួយសន្លឹកហើយផ្ញើរមកក្រុមការងាររៀបចំសន្និសីទតាមរយៈតេឡេក្រាម នៃវេទិកាពិភាក្សានីមួយៗ (ដែលបានបង្កើតជូនដោយក្រុមការងាររៀបចំសន្និសីទ) ដើម្បីរៀបចំខិត្តប័ណ្ណផ្សព្វផ្សាយ និងសម្រាប់អ្នកសម្របសម្រួលវេទិកាពិភាក្សានីមួយៗទុកជាឯកសារយោង ត្រឹមថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៤។

## វេទិកាពិភាក្សាទី១




## សំណួរមគ្គុទេសក៍

វេទិកាពិភាក្សាទី១ ផ្តោតជាពិសេសលើការពិនិត្យមើលភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចរបស់សាលា ដោយមានការសង្កត់ធ្ងន់ជាក់លាក់លើការគ្រប់គ្រងតាមសាលារៀន ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់សិស្ស។ ការពិភាក្សានឹងលើកឡើងពីចំណុចសំខាន់ៗដូចជា (១) ការស្វែងរកឱកាសសម្រាប់អ្នកដឹកនាំសាលា ដើម្បីបង្កើនភាពជាអ្នកដឹកនាំ និងជំនាញគ្រប់គ្រងរបស់ពួកគេ (២)ការវាយតម្លៃសមិទ្ធផល និងឧបសគ្គនានាដែលសាលារៀនជួបប្រទះក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀន (៣) ការពិនិត្យមើលពីវិធីសាស្ត្រដែលសាលារៀនទាក់ទាញការចូលរួមពីឪពុកម្តាយ និងសហគមន៍ក្នុងដំណើរការអភិបាលកិច្ច និងការសម្រេចចិត្ត និង (៤) តួនាទីនៃភាពជាអ្នកដឹកនាំរបស់សាលាក្នុងការរៀនសូត្ររបស់សិស្ស និងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀន។ វេទិកានេះ នឹងមានការចែករំលែកដោយវាគ្មិនកិត្តិយស ព្រមទាំងអ្នកសម្របសម្រួល ដែលមានបទពិសោធជាក់ស្តែង នឹងផ្តល់នូវទស្សនវិស័យដ៏មានតម្លៃសម្រាប់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសសម្រាប់អ្នកអភិវឌ្ឍគោលនយោបាយ និងអ្នកអនុវត្តជាក់ស្តែងក្នុងការសម្រេចចិត្តប្រកបដោយការយល់ដឹង ដើម្បីដោះស្រាយភាពស្មុគស្មាញជុំវិញការគ្រប់គ្រង និងភាពជាអ្នកដឹកនាំរបស់សាលាប្រកបដោយប្រសិទ្ធភាព។

សំណួរដែលបានស្នើឡើងសម្រាប់ការពិភាក្សាក្រុម៖

1) តើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានចូលរួមចំណែកអ្វីខ្លះ ដើម្បីគាំទ្រដល់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន?

2) ក្នុងនាមជានាយកសាលា តើលោក លោកស្រីមានឱកាសពង្រឹងភាពជាអ្នកដឹកនាំ និងជំនាញក្នុងការកែលម្អអភិបាលកិច្ចសាលារៀនយ៉ាងដូចម្តេចខ្លះ (បទពិសោធនៅក្នុងសាលានិងការគ្រប់គ្រងអាជីវកម្ម) មកទល់ពេលនេះទេ? ប្រសិនបើអ្នកមាន តើអ្នកទទួលបានឱកាស ឬវគ្គបណ្តុះបណ្តាលអ្វីខ្លះ?
3) តាមទស្សនៈរបស់លោក លោកស្រី តើអ្វីជាបញ្ហាប្រឈមសំខាន់ៗដែលសាលាបានជួបប្រទះក្នុងការធ្វើអោយប្រសើរឡើងនូវការសិក្សារបស់សិស្ស? តើយុទ្ធសាស្រ្តអ្វីខ្លះដែលទទួលបានជោគជ័យក្នុងការលើកកម្ពស់ការចូលរួមរបស់មាតាបិតា និងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀននិងដំណើរការធ្វើការសម្រេចចិត្តនៅសាលារបស់អ្នក?
4) តើការដឹកនាំសាលាប្រកបដោយប្រសិទ្ធភាពរួមចំណែកដល់ការអភិវឌ្ឍន៍វិជ្ជាជីវៈ និងសុខុមាលភាពរបស់គ្រូបង្រៀនយ៉ាងដូចម្តេច?
5) តើធ្វើដូចម្តេចដើម្បីទទួលបានការគាំទ្រ និងឧបត្ថម្ភពីឪពុកម្តាយ?
6) តើកត្តាអ្វីខ្លះដែលរួមចំណែកដល់ភាពជោគជ័យក្នុងការដឹកនាំសាលា?
7) តើក្រសួងអយក.មានគោលនយោបាយ និងគោលការណ៍ណែនាំ អ្វីខ្លះដើម្បីជួយដល់សាលារៀនក្នុងការទទួលយក និងអនុវត្តបច្ចេកវិទ្យា ?

## វេទិកាពិភាក្សាទី២



វេទិកាពិភាក្សាទី២ ផ្តោតលើការពិភាក្សាអំពីបទពិសោធដែលសាលារៀនបានឆ្លងកាត់ទាក់ទងនឹងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដោយផ្តោតលើបញ្ហាប្រឈម និងឧត្តមានុវត្តន៍។ ផ្នែកគន្លឹះៗដែលត្រូវពិភាក្សារួមមាន៖ (១) បញ្ហាប្រឈមក្នុងការរៀបចំការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន (២) ឧត្តមានុវត្តន៍ ពីសាលារៀនទាក់ទងនឹងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ (៣)ការចូលរួមពីភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ និង (៤) គំរូនៃការបង្វឹក និងប្រឹក្សាយោបល់ប្រកបដោយប្រសិទ្ធភាព។

សំណួរដែលបានស្នើឡើងសម្រាប់វេទិកាពិភាក្សាទី២៖

1) ផ្អែកលើបទពិសោធ និងទស្សនៈរបស់លោក លោកស្រី តើអ្វីជាបញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំក្នុងចំណោមគ្រូបង្រៀននៅកម្ពុជា? តើអ្វីជាមូលហេតុនៃបញ្ហាប្រឈមទាំងនេះ? តើយើងអាចដោះស្រាយដោយរបៀបណា?
2) តើគំរូនៃការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំប្រកបដោយប្រសិទ្ធភាពអ្វីខ្លះដែលអ្នកបានឮ ឬទទួលយក? តើកត្តាអ្វីខ្លះដែលធ្វើឱ្យគំរូទាំងនោះមានប្រសិទ្ធភាព?
3) ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ ដើរតួជាអ្នកលើកទឹកចិត្តក្នុងការរក្សាគ្រូបង្រៀន។ ទោះយ៉ាងណាក៏ដោយ នៅតំបន់ជនបទ វាអាចពិបាកក្នុងការដាក់ចេញនូវគំនិតផ្តួចផ្តើមថ្មីទាក់ទងនឹងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។ តាមយោបល់របស់អ្នក តើរាជរដ្ឋាភិបាល អាចដោះស្រាយបញ្ហានេះ ដោយរបៀបណា?
4) តើអ្នកគិតថាវិស័យឯកជន (ឧ.សាលាឯកជន ឬក្រុមហ៊ុន)គួរតែចូលរួមក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដោយរបៀបណា?
5) តើវិស័យឯកជនគួរត្រូវបានអនុញ្ញាតឱ្យដំណើរការគ្រឹះស្ថានបណ្តុះបណ្តាលបង្រៀនផ្ទាល់ខ្លួន ដើម្បីអាចធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនទាំងការបណ្តុះបណ្តាលដំបូង (Pre-service) និងការបណ្តុះបណ្តាលបន្ត (In-service) និងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈដែរឬទេ?
6) គំរូ នៃការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំថ្មីដែលបានស្នើឡើងដើម្បីជំនួសគំរូ cascade គឺការបង្វឹក និងប្រឹក្សាយោបល់។ ដោយពិចារណា លើគុណសម្បត្តិ និង គុណវិបត្ត តើអ្នកគិតថា គំរូនៃការបង្វឹក និងប្រឹក្សាយោបល់មានប្រសិទ្ធភាព ដោយរបៀបណា?

## វេទិកាពិភាក្សាទី៣




វេទិកាពិភាក្សាទី៣ ផ្តោតលើតួនាទីរបស់រដ្ឋាភិបាល និងវិស័យឯកជនក្នុងការគាំទ្រការរួមបញ្ចូលនៃ Edtech ក្នុងការរៀន និងបង្រៀន។ វេទិកាពិភាក្សានេះ នឹងជជែកជុំវិញផ្នែកសំខាន់ៗដូចជា (១) គំនិតផ្តួចផ្តើមរបស់ក្រសួងពាក់ព័ន្ធក្នុងការគាំទ្រសាលារៀនឬប្រព័ន្ធអប់រំក្នុងសមាហរណកម្មបច្ចេកវិទ្យា និងការសហការគ្នារវាងតួអង្គនានា (២) ភាពជោគជ័យ និងបញ្ហាប្រឈមក្នុងការរួមបញ្ចូល Edtech (៣) តួនាទី និងភាពជាដៃគូរវាងវិស័យឯកជន និងរដ្ឋាភិបាលក្នុងការលើកកម្ពស់ការដាក់បញ្ចូលឌីជីថលក្នុងវិស័យអប់រំ និង (៤) តួនាទីនៃបច្ចេកវិទ្យាក្នុងការកែលម្អការសិក្សា និងសមធម៌។

1) ផ្អែកលើបទពិសោធការងាររបស់ស្ថានប័ន និងវាគ្មិនផ្ទាល់ តើបច្ចេកវិទ្យានឹងមានផលវិជ្ជមាន ឬអវិជ្ជមានចំពោះការអប់រំ? សូមជួយចែករំលែកខ្លីៗ។ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានបង្កើត ផែនទីបង្ហាញផ្លូវមួយចំនួនរួមទាំងផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាអប់រំផង។ តើផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាអប់រំនោះអាចនឹងត្រូវប្រើដោយភាគីណាខ្លះ? ប្រើដោយរបៀបណា ដើម្បីបង្កើនភាពធន់ និងគុណភាពអប់រំ? តើក្រសួងមានផែនការតាមដានការប្រើប្រាស់ផែនទីបង្ហាញផ្លូវដោយរបៀបណាដែរ?
2) ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បានបង្កើតធនធានឌីជីថលជាច្រើន ដូចជា MoEYS App ដូចជា Sala Digital, E-learning Apps, Durakseksa, CPD Platform, Student Capacity Assessment (exam.moeys.gov.kh), EBC, BEEP ជាដើម។

តើការប្រើប្រាស់ធនធានទាំងនេះនឹងចូលរួមចំណែកដល់ការធានាភាពធន់ និងពង្រឹងគុណភាព ដោយរបៀបណាដែរ? តើការប្រើប្រាស់ធនធានទាំងនេះមានវិសាលភាពកម្រិតណា ដូចជា សាលារៀននៅតំបន់ខុសៗគ្នា? តើមានការវាយតម្លៃអំពីប្រសិទ្ធភាពនៃធនធានទាំងនេះឬទេ? បើមានតើលទ្ធផលយ៉ាងណា? បើមិនទាន់ទេ តើនាយកដ្ឋានគិតថានឹងធ្វើការវាយតម្លៃដែរ ឬទេ?

3) យើងដឹងហើយថា គោលនយោបាយល្អយ៉ាងណាក៏ដោយ ធនធានសិក្សាល្អយ៉ាងណាក៏ដោយ បើគ្មានបណ្តាញតភ្ជាប់ទៅដល់អ្នកប្រើប្រាស់នោះទេ គោលនយោបាយ និងធនធាទាំងនោះមិនអាចជួយយើងសម្រេចគោលដៅបានទេ។ តើក្រុមហ៊ុនស្មាតបានអភិវឌ្ឍប្រព័ន្ធអ្វីខ្លះដើម្បីដើម្បីនាំធនធានឌីជីថលទៅដល់អ្នកប្រើប្រាស់ ដូចជា Mobile Data ប្រព័ន្ធគ្រប់គ្រងសាលារៀន ឬគ្រប់គ្រងការបង្រៀន? តើវិសាលភាពនៃការគ្របដណ្តប់បណ្តាញអ៊ីនធឺណិតមានកម្រិតណា មិនរាប់តែក្រុមហ៊ុនស្មាតទេ? តើបទពិសោធនៃការប្រើបណ្តាញ Mobile Data និងប្រព័ន្ធគ្រប់គ្រងការបង្រៀន និងរៀន ដូចជា BEEP ផ្តល់ក្តីសង្ឃឹមកម្រិតណាសម្រាប់ពង្រឹងគុណភាពអប់រំ និងភាពធន់នៅកម្រិតផ្សេងៗទៀតចាប់ពីបឋម រហូតដល់ឧត្តមសិក្សា?

4) យើងទទួលស្គាល់ទាំងអស់គ្នាថា CDRI ជាវិទ្យាស្ថានស្រាវជ្រាវ ដែលមានវ័យចំណាស់ជាងគេនៅកម្ពុជា ហើយត្រូវបានគេទទួលស្គាល់នៅកម្រិតជាតិ តំបន់ និងអន្តរជាតិ។ ការប្រើប្រាស់បច្ចេកវិទ្យាពិតមែនតែមានការវិវត្តខ្លាំង ប៉ុន្តែមិនមានមនុស្សគ្រប់គ្នាសុទ្ធតែយល់ឃើញអត្ថប្រយោជន៍របស់វាទេ។ សារលិខិតលោកស្រី Audrey Azoulay អគ្គនាយិកាអង្គការយូណេស្កូ ក្នុងឱកាសទិវាអន្តរជាតិដើម្បីការសិក្សាបែបឌីជីថល ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ បានបង្ហាញកង្វល់ខ្លាំងអំពីម្ហូតអប់រំ ដែលអាចនឹងកើតមានឡើងប្រសិនបើលិខិតបទដ្ឋានគតិយុត្ត និងយន្តការគាំទ្រមិនមានគ្រប់គ្រាន់។ តើវិទ្យាស្ថានបានស្រាវជ្រាវប្រធានបទបច្ចេកវិទ្យាអប់រំអ្វីខ្លះកន្លងមក? តើលទ្ធផលស្រាវជ្រាវទាំងនោះបានឆ្លុះបញ្ចាំងសម្រាប់បង្កើតគោលនយោបាយ និងអន្តរាគមន៍អ្វីខ្លះ? តើបច្ចេកវិទ្យាអប់រំគួរតែមានទម្រង់បែបណាដើម្បីធានាថា វាអាចជួយពន្លឿន និងធ្វើឱ្យការរៀបចំគោលនយោបាយ និងអន្តរាគមន៍បានទាន់ពេលដើម្បីពង្រឹងភាពធន់ និងបង្កើនគុណភាព ជាងការដែលយើងមិនប្រើ?

# វេទិកាពិភាក្សាទី៤




វេទិកាទី៤ ផ្តោតលើកត្តាដែលរួមចំណែកដល់ឧត្តមានុវត្តន៍នៃភាពជាដៃគូសាធារណៈនិងសហគមន៍នៅក្នុងបរិបទសាលារៀននៅប្រទេសកម្ពុជា និងបញ្ហាប្រឈមនានាដែលរារាំងការអនុវត្ត និងទិសដៅទៅមុខសម្រាប់ការកែលម្អ។ ដូច្នេះ វិស័យសំខាន់ៗខាងក្រោមនឹងត្រូវបានគ្របដណ្តប់ក្នុងអំឡុងពេលពិភាក្សា៖ ១) អត្ថន័យនៃភាពជាដៃគូសាធារណៈនិងសហគមន៍តាមទស្សនៈនិងការយល់ឃើញរបស់វាគ្មិន និងសកម្មភាពសម្រាប់ការអនុវត្ត ២) យន្តការជោគជ័យដែលមានស្រាប់ ដើម្បីលើកកម្ពស់ភាពជាដៃគូសាធារណៈ និងសហគមន៍នៅក្នុងបរិបទសាលារៀននៅប្រទេសកម្ពុជា ៣) តួនាទីរបស់ភាគីពាក់ព័ន្ធក្នុងការគាំទ្រ និងនិរន្តរភាពភាពជាដៃគូសាធារណៈ និងសហគមន៍ និង ៤) បទពិសោធ (What-Works and What-does-not-work) បញ្ហាប្រឈម និងទិសដៅក្នុងការលើកកម្ពស់ភាពជាដៃគូសាធារណៈនិងសហគមន៍។

1) តើអ្នកអាចពណ៌នាអំពីអត្ថន័យនៃភាពជាដៃគូសាធារណៈនិងសហគមន៍នៅក្នុងបរិបទសាលារៀននៅកម្ពុជាបានដែរឬទេ? តើការដាក់ចេញជាសកម្មភាពសម្រាប់សាលារៀនអនុវត្តយ៉ាងដូចម្តេច? ហេតុអ្វីបានជាសាលារៀនត្រូវការភាពជាដៃគូសាធារណៈនិងសហគមន៍?
2) តាមពិត តើអ្នកអាចប្រាប់អ្នកចូលរួមអំពីការអនុវត្ត ឬយន្តការដែលមានស្រាប់ ដើម្បីកសាងភាពជាដៃគូសាធារណៈនិងសហគមន៍បានដែរឬទេ? សូមគូសបញ្ជាក់ពីម៉ូដែលឬការអនុវត្តជោគជ័យសំខាន់ៗមួយចំនួននៃភាពជាដៃគូសាធារណៈនិងសហគមន៍?
3) តើអ្នកណាខ្លះគួរចូលរួមក្នុងភាពជាដៃគូសាធារណៈនិងសហគមន៍?
4) តើភាគីពាក់ព័ន្ធមានតួនាទីអ្វីខ្លះក្នុងការគាំទ្រនិងនិរន្តរភាពភាពជាដៃគូសាធារណៈនិងសហគមន៍?

5) តើភាពជាដៃគូសាធារណៈនិងសហគមន៍អាចរួមចំណែកក្នុងការលើកកម្ពស់ការអភិវឌ្ឍសាលារៀន និងលទ្ធផលសាលារៀនយ៉ាងដូចម្តេច?

6) តាមបទពិសោធន៍របស់អ្នក តើអ្វីជាការអនុវត្តល្អនិងមិនល្អក្នុងការលើកកម្ពស់ភាពជាដៃគូសាធារណៈ និងសហគមន៍នៅកម្រិតសាលារៀន? តើបញ្ហាប្រឈមអ្វីខ្លះដែលមិនទាន់ដោះស្រាយ? តើជំហានបន្ទាប់អ្វីខ្លះដែលអ្នកចង់ស្នើដើម្បីកែលម្អភាពជាដៃគូសាធារណៈនិងសហគមន៍?

## ៦. កម្មវិធីនៃសន្និសីទគោលនយោបាយអប់រំ លើកទី៤

## ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤

០៧:០០-០៨:០០ នាទី **ចុះឈ្មោះ**

០៨:០០-០៩:០០ នាទី **ពិធីបើក និងកិច្ចចាប់ផ្តើមកម្មវិធី**

**-គោរពភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា**

**-មតិស្វាគមន៍**

លោកស្រីបណ្ឌិត **អេង នេត្រា** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

**-ចំណាប់អារម្មណ៍** ឯកឧត្តម **Justin Whyatt** ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា

០៩:០០-០៩:៣០ នាទី **សុន្ទរកថាបើកសន្និសីទគោលនយោបាយអប់រំ៖ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់និងធានាគុណភាពអប់រំ**

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

០៩:៤៥-១០:០០ នាទី -សម្រាក

១០:០០-១០:៤៥ នាទី **បទបង្ហាញគន្លឹះ**

លោកបណ្ឌិត **សុខ សុភក្តិ** នាយកប្រតិបត្តិរងនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

១០:៤៥-១១:៣០ នាទី **បទបង្ហាញគន្លឹះ**

**Dr. David Ng Foo Seong** ព្រឹទ្ធបុរសរងផ្នែកគុណភាពសិក្សា នៃវិទ្យាស្ថានជាតិអប់រំ ប្រទេសសឹង្ហបុរី

១១:៣០-១៣:៣០នាទី សម្រាកអាហារថ្ងៃត្រង់

១៣:៣០-១៥:០០ នាទី **វេទិកាពិភាក្សាទី១៖ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀនល្អ ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស**

**អ្នកសម្របសម្រួល៖** លោក **អ៊ុល រុន** ទីប្រឹក្សាជាតិជាន់ខ្ពស់អង្គការខេប(KAPE)

**វាគ្មិន៖** ១.ឯកឧត្តមបណ្ឌិត **ហ៊ុល សៀងហេង** អនុរដ្ឋលេខាធិការក្រសួង វ.ប.ន

២.លោក **សឿន ទ៉ាន់** នាយកវិទ្យាល័យហ៊ុន សែនកំពង់ចាម

៣.លោក **សឿន រដ្ឋា** នាយកវិទ្យាល័យសម្តេចកិត្តិព្រឹទ្ធបណ្ឌិតប៊ុនរ៉ានី ហ៊ុន សែន ដើមឫស

៤.លោក **ផាត់ ហ៊ុច** តំណាងមកពីសាលាប៉ែលធីអន្តរជាតិ

៥.លោក **ដូមិនិក ហ្សាច** នាយកប្រចាំប្រទេស អង្គការសប្បុរសធម៌ឡៃហ្គឺ

១៥:០០-១៥:១៥នាទី **-សម្រាក**

១៥:១៥-១៧:០០នាទី **វេទិកាពិភាក្សាទី២៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ តាមរយៈការបង្វឹក និងប្រឹក្សាយោបល់**

**អ្នកសម្របសម្រួល៖** លោកបណ្ឌិត **ខាន់ មុន្ធាន់** មន្ត្រីអប់រំជាន់ខ្ពស់ អង្គការ UNESCO

**វាគ្មិន៖** ១.លោកបណ្ឌិត **ឈុក ច័ន្ទឆាយា** អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

២.លោកបណ្ឌិត **ជា សត្យា** អ្នកស្រាវជ្រាវមកពីវិទ្យាស្ថាន CDRI

៣.លោក **គីង ពៅ** នាយកគ្រប់គ្រងអង្គការទស្សនៈឥតព្រំដែន

៤.លោក **កែវ មនោ** ទីប្រឹក្សាអប់រំ អង្គការវីអូប៊ី (VVOB)

**៥.**លោកស្រី **ឆួក ណារ៉ា** គ្រូបង្រៀនល្អ វិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម

**ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤**

០៧:៣០-០៨:០០ នាទី **-ចុះឈ្មោះ**

០៨:០០-០៩:៤៥ នាទី **វេទិកាពិភាក្សាទី៣៖ តើបច្ចេកវិទ្យាជួយកាត់បន្ថយឬបង្កើនគម្លាត?តើយើងត្រូវធ្វើដូចម្តេចដើម្បីប្រើប្រាស់បច្ចេកវិទ្យាឱ្យបានប្រសើរជាងមុនក្នុងការលើកកម្ពស់ការសិក្សា**?

**អ្នកសម្របសម្រួល៖** លោកបណ្ឌិត **ឈិញ ស៊ីថា** អ្នកស្រាវជ្រាវឯករាជ្យ

**វាគ្មិន៖** ១.លោកបណ្ឌិត **សៀវ សុខលី** អគ្គនាយករង នៃអគ្គនាយកដ្ឋាន វ.ប.ន

២.លោក **គៃល តារុណា** ប្រធានផ្នែកគោលនយោបាយនៃអគ្គលេខាធិការដ្ឋាន ការអប់រំពេញមួយជីវិត និងជាអនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

៣.លោកបណ្ឌិត **ជា ផល** អ្នកស្រាវជ្រាវជាន់ខ្ពស់ មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វ.ប.ស.អ)

៤.កញ្ញា **ចែម ស្រីអឿន** ប្រធានកិច្ចការសាធារណៈ នៃក្រុមហ៊ុនស្មាត

០៩:៤៥-១០:០០ នាទី សម្រាក

១០:០០-១១:៣០ នាទី **វេទិកាពិភាក្សាទី៤៖ឧត្តមានុវត្តន៍ នៃភាពជាដៃគូសាធារណៈ និងសហគមន៍**

**អ្នកសម្របសម្រួល៖** លោក បណ្ឌិត **ឌិន សំអាត** អនុប្រធាននាយកដ្ឋានគោលនយោបាយ

| | |
|---|---|
| វាគ្មិន៖ | ១.លោកបណ្ឌិត **ភាន់ ពុទ្ធី** អនុប្រធាននាយកដ្ឋានបឋមសិក្សា<br>២.លោក **កែវ សារ៉ាត់** ទីប្រឹក្សាគម្រោង GEIP (ក្រសួង អយក.)<br>៣.លោក **លី យ៉ានី** នាយកអនុវិទ្យាល័យ សំ ប៉ាន ខេត្តកណ្ដាល<br>៤.លោកស្រី **ចេន ខេណា** តំណាងគណៈកម្មការគ្រប់គ្រងសាលារៀនល្អ ខេត្តកំពង់ចាម |
| ១១:៣០-១៣:៣០ | សម្រាកអាហារថ្ងៃត្រង់ |
| ១៣:៣០-១៥:៣០ | **ការកំណត់របៀបវារៈស្រាវជ្រាវគោលនយោបាយ**<br>• បទបង្ហាញរួមគ្នាលើប្រធានបទស្រាវជ្រាវដែលមានសក្ដានុពល (CDRI)<br>• កិច្ចពិភាក្សាសម្រាប់ការសហការនាពេលអនាគត |
| ១៥:៣០-១៥:៤៥ | សម្រាក |
| ១៥:៤៥-១៧:០០ | **ពិធីបិទ៖ អនុសាសន៍ទៅលើយុទ្ធសាស្ត្រនិងគោលនយោបាយ សំខាន់ៗ និងបិទកម្មវិធី**<br>• បទបង្ហាញសង្ខេប និងបិទកម្មវិធីដោយ<br>លោក **ភខ សុផាន់ណា** អនុប្រធាននាយកដ្ឋានគោលនយោបាយ នៃក្រសួងអប់រំ យុវជន និងកីឡា |

## ៧. សមាសភាពចូលរួម

សមាសភាពអញ្ជើញចូលរួមសរុបប្រមាណជា១១៨៧ នាក់ ក្នុងនោះមានចូលរួមដោយផ្ទាល់ ៨៧៤នាក់ (វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួលសរុប ២២ នាក់) និងតាមរយៈអនឡាញប្រមាណ ៣១៣ នាក់ ដែលជាអ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្តគោលនយោបាយគ្រប់លំដាប់ថ្នាក់រួមមានថ្នាក់ដឹកនាំក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនគ្រប់កម្រិតសិក្សា មន្ទីរ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន(ដូចមានបញ្ជីជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ)។

## ៨. សុន្ទរកថាបើកកម្មវិធី

# សុន្ទរកថា

## ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
## ថ្លែងក្នុងសន្និសីទគោលនយោបាយអប់រំលើកទី៤ ស្តីពី
## «ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគត
## ដើម្បីកសាងភាពធន់ និងធានាគុណភាពអប់រំ »
## វិទ្យាស្ថានជាតិអប់រំ, ថ្ងៃទី ២០-២១ ខែមីនា ឆ្នាំ២០២៤

- ឯកឧត្តម Justin Whyatt ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា
- លោកស្រីបណ្ឌិត អេង នេត្រា នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍកម្ពុជា (CDRI)
- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អគ្គនាយក អគ្គនាយករង និងប្រធានអង្គភាព
- លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ទីរអប់រំខេត្ត ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន
- អង្គពិធីទាំងមូល ជាទីរាប់អាន!

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយ ដោយបានចូលរួមជាអធិបតីក្នុងសន្និសីទគោលនយោបាយអប់រំលើកទី៤ ស្តីពី **«ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និងធានាគុណភាពអប់រំ»** ដែលរៀបចំដោយនាយកដ្ឋានគោលនយោបាយ នៃក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)។ នេះគឺជា ឱកាសដ៏មានសារៈសំខាន់មួយ ដែលបានប្រមូលផ្តុំធនធានមនុស្ស និងគ្រប់ភាគីពាក់ព័ន្ធ ក្នុងការគិតគូរពិចារណា និងពិភាក្សាលើបញ្ហាពាក់ព័ន្ធនឹងការអប់រំ ដើម្បីកំណត់ឱ្យបាននូវចរិតលក្ខណៈនៃប្រព័ន្ធអប់រំនៅកម្ពុជា។ ក្នុងបរិបទនៃការអប់រំសតវត្សរ៍ទី២១ គឺមានភាពស្មុគ្រស្មាញជាច្រើន ដែលត្រូវធ្វើបរិវត្តកម្ម ដូចជាការអភិវឌ្ឍកម្មវិធីសិក្សា ការកែលម្អវិធីសាស្ត្ររៀន និងបង្រៀន ការអប់រំស្វែម ការអប់រំតាមបែបឌីជីថល ការអភិវឌ្ឍបំណិន និងចរិយាសម្បទាដល់សិស្សានុសិស្ស

ជាដើម។ ទន្ទឹមនឹងនេះ យើងត្រូវត្រៀមខ្លួនដើម្បីសម្រេចបាននូវគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា តាមរយៈការអនុវត្តនូវកម្មវិធីកំណែទម្រង់កម្រិតក្រសួង និងកម្រិតជាតិឱ្យឆ្លើយតបនឹងបរិការជាតិនិងអន្តរជាតិ។

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី**
- **អង្គពិធីទាំងមូល ជាទីមេត្រី!**

ដើម្បីឆ្លើយតបទៅនឹងបដិវត្តកម្មឧស្សាហកម្ម ៤.០ និងសម្រេចឱ្យបាននូវចក្ខុវិស័យ កម្ពុជាក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អាទិភាពទៅលើការអប់រំ ដោយបានដាក់បញ្ចូល «**ការពង្រឹងគុណភាពអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**» ក្នុងមុំទី១ នៃបញ្ចកោណទី១ ដែលសំដៅដល់ «**ការអភិវឌ្ឍធនធានមនុស្ស**» និងជាបុរេលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញនិងការធ្វើពិពិធកម្មសេដ្ឋកិច្ចប្រកបដោយកំណើន បរិយាបន្ន និងសង្គតិភាព។

ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តនូវយុទ្ធសាស្ត្រថ្មីៗក្នុងគោលដៅធ្វើបរិវត្តកម្មសាលារៀនឱ្យក្លាយទៅជា **សាលារៀនគំរូ**។ គំនិតផ្តួចផ្តើមនេះ មានគោលបំណងលើកកម្ពស់គុណភាពនៃការបង្រៀននិងរៀន តាមរយៈការបង្កើតឧបករណ៍ជាគំរូ ដែលដើរតួនាទីសំខាន់សម្រាប់វាស់វែងនិងប្រៀបធៀប សម្រាប់ឱ្យសាលារៀននានាអាចយកជាគំរូបាន។ យុទ្ធសាស្ត្រស្នូលនៃស្តង់ដាសាលារៀនគំរូ មានចំនួន៥ ដែលរួមមាន៖ ១.លទ្ធផលសិក្សារបស់សិស្ស ២.ការរៀននិងបង្រៀន ៣.ការចូលរួមរបស់សហគមន៍ ៤.ប្រតិបត្តិការនិងរដ្ឋបាលសាលារៀន និង ៥. គណនេយ្យភាពរបស់សាលារៀន។

លើសពីនេះទៀត ក្រសួងបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំ តាមរយៈការអប់រំឌីជីថលដែលជាមធ្យោបាយមួយក្នុងការលើកកម្ពស់នូវលទ្ធផលសិក្សារបស់សិស្ស និងការគ្រប់គ្រងតាមសាលារៀន។ ដោយមើលឃើញអំពីសក្តានុពលដ៏ ធំធេងនៃបច្ចេកវិទ្យាក្នុងបរិវត្តកម្មវិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើវិនិយោគយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាលគ្រូបង្រៀន និងការអភិវឌ្ឍធនធានឌីជីថល ដើម្បីឆ្លើយតបនឹងគោលនយោបាយរដ្ឋាភិបាលឌីជីថល និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។ គំនិតផ្តួចផ្តើមសំខាន់ៗដែលក្រសួងបានដាក់ឱ្យអនុវត្តសម្រាប់សាលារៀន ដើម្បីទាញយកអត្ថប្រយោជន៍ពីសក្តានុពលនៃសម្ភារៈ និងមធ្យោបាយឌីជីថលទាំងនោះតួយ៉ាង ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងសាលារៀន (School Information System – SIS) និងប្រព័ន្ធថ្នាលសិក្សា ព្រមទាំងកម្មវិធីសិក្សាតាមអនឡាញដ៏សម្បូរបែប។

បន្ថែមពីនេះទៀត ក្រសួងក៏បានផ្តោតសំខាន់លើការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព និងការចូលរួមរបស់សហគមន៍ ក្នុងការជំរុញឆ្ពោះទៅមុខនូវឧត្តមានភាពនៃប្រព័ន្ធអប់រំ និងគណនេយ្យភាពរបស់សាលារៀន។ ការណ៍នេះត្រូវបានស្តែងចេញតាមរយៈ ការបង្កើតនូវគណៈកម្មការគ្រប់គ្រងសាលារៀនក្នុងគោលដៅពង្រឹងនូវការចូលរួមរបស់សហគមន៍ និងលើកកម្ពស់ការសម្រេចចិត្តនៅកម្រិតសាលារៀន។ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់លើការផ្តល់អំណាចដល់ថ្នាក់ដឹកនាំសាលារៀន និងអ្នកពាក់ព័ន្ធក្នុងការបំពេញមុខងារយ៉ាងសកម្មលើអភិបាលកិច្ចសាលារៀន និងដំណើរការរៀនសូត្រ។ ជាមួយគ្នានេះផងដែរ ការពង្រឹងកិច្ច

សហប្រតិបត្តិការរវាងសាលារៀន និងសហគមន៍ ក្រសួងមានគោលដៅបង្កើតនូវបរិស្ថានសិក្សាដែលគាំទ្រដល់ការសិក្សា និងសុខមាលភាពរបស់សិស្ស។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមផ្តល់នូវអនុសាសន៍គន្លឹះដល់អង្គសន្និសីទដូចតទៅ៖

១. ត្រូវឈ្វេងយល់អំពីបញ្ហានៅកម្រិតសាលារៀនឱ្យបានច្បាស់លាស់ ការរៀននិងបង្រៀន ការចូលរួមរបស់សហគមន៍ ដោយឆ្លុះបញ្ចាំងនឹងលទ្ធផលសិក្សារបស់សិស្ស

២. សូមចូលរួមរិះរកនូវនវានុវត្តន៍សម្រាប់សាលារៀនក្នុងការសម្រេចបាននូវភាពធន់របស់សាលារៀន និងគុណភាពសិក្សា

៣. ពង្រឹងសហប្រតិបត្តិការ និងភាពជាដៃគូរវាងរដ្ឋ និងឯកជន ព្រមទាំងអ្នកពាក់ព័ន្ធក្នុងវិស័យអប់រំ ដើម្បីទាញយកនូវសក្តានុពលផ្តល់ប្រយោជន៍ទៅវិញទៅមក។

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី**
- **អង្គពិធីទាំងមូល ជាទីមេត្រី!**

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សន្និសីទនាថ្ងៃនេះនឹងញ៉ាំងឱ្យមានការពិភាក្សាគ្នាយ៉ាងផុសផុល អំពី ការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និងជានាគុណភាពអប់រំ ដើម្បីទទួលបានជាតុចូលបន្ថែមទៀត ក៏ដូចជាការដោះស្រាយលើបញ្ហាប្រឈមនានាផងដែរ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ និងសូមថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល ដែលបានរៀបចំ និងចូលរួមសន្និសីទនេះ ឱ្យដំណើរការបាននាពេលនេះ។

ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូល សូមសមប្រកបនឹងពុទ្ធពរ ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើកសន្និសីទគោលនយោបាយអប់រំលើកទី៤ ស្តីពី **«ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និងជានាគុណភាពអប់រំ»** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

# 4th National Education Forum on

# “Towards Future-Ready Schools: Building Resilience and Ensuring Quality”

**National Institute of Education, 20 March 2024**

## KEY POINTS FOR SPECIAL REMARKS BY:

**H.E Justin Kevin Whyatt**
**Australian Ambassador to Cambodia**

**(8:50-9:00 AM)**

- **H.E Dr Hang Chuon Naron**, Deputy Prime Minister, Minister of Education, Youth and Sport
- **Dr Eng Netra**, Executive Director, CDRI
- **Dr Bo Chankouklika**, Director of the Department of Policy of the Minister of Education, Youth and Sport
- Excellencies and Distinguished participants,
- Lokrou/Neak Krou (male/female teachers)

Arun Soursdey/Good morning to you all.

It is my pleasure to be here today and join you all in opening the 4th National Education Policy Forum on “Towards Future-Ready Schools: Building Resilience and Ensuring Quality.” The forum is co-organised by *the Department of Policy of the Ministry of Education, Youth and Sport* and *the Cambodia Development Resource Institute (CDRI)*, with financial support from the Australian Department of Foreign Affairs and Trade (DFAT) through The Asia Foundation’s Ponlok Chomnes 2: Data and Dialogue for Development in Cambodia program. It is utilised as a platform for participants, particularly representatives from relevant ministries, educational establishments, development partners, think tanks, civil societies, and the private sector, to discuss and share views on various topics, all of which are related to the development/improvement of the education sector in Cambodia. This year, we specifically discuss how relevant stakeholders can play roles in supporting schools to build their resilience and be ready for the uncertainty or shock that could occur unpredictably in the coming years.

We greatly appreciate the efforts made by the Department of Policy and CDRI to make this policy dialogue happen, and my sincere thanks also go to His Excellency Dr. Naron for your presence today and guidance, as always. Your presence and senior leadership of MoEYS are essential for adopting and implementing relevant policies, strategies and concrete actions that emerged from the forum.

Excellencies and distinguished participants,

I would also like to take this opportunity to briefly talk about our commitment to the development of the education sector in Cambodia.

PLEASE TALK ABOUT THE EMBASSY'S DEVELOPMENT ASSISTANCE (EDUCATION) AND CONNECT TO THE FOLLOWING PONLOK CHOMNES INITIATIVE.

- e.g., the Australian Award Scholarship to Cambodia
- e.g. CDRI's Higher Education Policy Research & Influencing in Cambodia: A Contribution to the Development & Implementation of CDRI's Education Programme (2015-2019), supported by DFAT.

Another initiative that we have taken so far is the Ponlok Chomnes: Data and Dialogue for Development in Cambodia, implemented by The Asia Foundation. This program aims to support public policy-making through evidence-informed decision-making and inclusive dialogue. The first phase was implemented between 2019 and 2023 and has helped build the capacity of Cambodian institutions to conduct quality research and contribute to policy recommendations. Currently, we are in the second phase (2023-2027), and we aim to advance the integration of evidence-informed decision-making and inclusive dialogue into public policy processes by focusing on the practical application of existing approaches and striving to establish evidence-informed decision-making as a routine practice in the governance of Cambodia. Integrating gender equality, disability and social inclusion, and climate change throughout the program is also our primary goal.

Today's forum is a part of this initiatitve.

In alignment with the program's key objectives of promoting inclusive and collaborative policy dialogue processes, this forum takes place to offer opportunities for stakeholders and practitioners to discuss issues related to education quality improvement, such as the ideal school leadership and school governance models for improved students' learning outcomes, the effectiveness of teachers' continuous professional development programmes, the critical role of technology in improving education services deliveries, and the best practices of public-community partnerships. Not only this, but the forum will also offer chances for participants to network and stay connected with each other. Therefore, I hope everyone will take this chance to socialise and exchange ideas toward the development of the education sector in Cambodia.

I wish everyone success and hope you all have a fruitful discussion today and tomorrow.

ORKUN (Thank you)!

## សុន្ទរកថាស្វាគមន៍

## លោកស្រីបណ្ឌិត អេង នេត្រា
## នាយិកាប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

សូមគោរព និងជម្រាបសួរ៖

- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តម **Justin Kevin Whyatt** ឯកអគ្គរាជទូតអូស្ត្រាលី ប្រចាំកម្ពុជា
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី** តំណាងក្រសួង និងមន្ទីរអប់រំទូទាំងប្រទេស
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី** តំណាងដៃគូអភិវឌ្ឍ
- **លោក លោកស្រី អ្នកនាង កញ្ញា សមាជិក និងសមាជិកា** អង្គសន្និសីទទាំងមូល

នាព្រឹកនេះ ខ្ញុំ មានកិត្តិយស និងសេចក្តីសោមនស្សរីករាយដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងការធ្វើសុន្ទរកថាស្វាគមន៍ក្នុង សន្និសីទគោលនយោបាយអប់រំ ដែលផ្តោតទៅលើប្រធានបទ «**ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាព និងជានាគុណភាពអប់រំ**» ដែលជា កិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋានគោលនយោបាយ (DoPo) នៃក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានបណ្តុះ បណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ។ នេះគឺជាលើកទីបួនហើយ ដែលយើងបានរួមដៃគ្នាធ្វើសន្និសីទនេះឡើង ក្នុងគោលបំណងបង្កើតឱកាសឱ្យភាគីពាក់ព័ន្ធទាំងអស់បានបង្ហាញ និងពិភាក្សាអំពីវឌ្ឍនភាពនៃវិស័យអប់រំ ក៏ដូចជា ស្វែងរកគំនិតថ្មីៗបន្ថែមទៀតដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើង។ ខ្ញុំសង្ឃឹមថា លទ្ធផលនៃសន្និសីទអប់រំនេះ នឹងផ្តល់ជាធាតុចូលមួយចំនួនដល់កិច្ចពិភាក្សាលើកំណែទម្រង់អប់រំសំខាន់ៗ នៅក្នុងសន្និបាតអប់រំក្នុងឆ្នាំ២០២៤ ដែលនឹងធ្វើឡើងក្នុងពេលឆាប់ៗខាងមុខនេះ និងជួយកំណត់បញ្ហាអាទិភាពសម្រាប់អនុវត្តគោលនយោបាយអប់រំក្នុងឆ្នាំនេះ និងឆ្នាំបន្តបន្ទាប់ទៀត។

ក្នុងឆ្នាំកន្លងមក វិទ្យាស្ថាន CDRI បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា តាមរយៈនាយកដ្ឋានគោលនយោបាយ ធ្វើការស្រាវជ្រាវមួយចំនួនទាក់ទងនឹងវិស័យអប់រំ ដូចជា «**ការបង្រៀន និងរៀនក្នុងបរិបទនៃការរាតត្បាតជំងឺកូវីត-១៩**» និងថ្មីៗនេះអំពី «**គម្លាតសមត្ថភាពសិក្សារវាងសិស្សស្រី និងសិស្សប្រុសនៅកម្រិតមធ្យមសិក្សា**»។ ក្រុមការងារស្រាវជ្រាវ នឹងនាំយករបកគំហើញ និងមេរៀនពីការសិក្សាចែករំលែកក្នុងសន្និសីទគោលនយោបាយនេះ។ លើសពីនេះ វិទ្យាស្ថាន CDRI រីករាយ និងត្រៀមខ្លួនជានិច្ច ក្នុងការសហការជាមួយ

ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើការស្រាវជ្រាវ ដើម្បីរកភស្តុតាងជួយដល់ការកសាង និងអនុវត្តគោលនយោបាយ ក៏ដូចជា ការរៀបចំកិច្ចពិភាក្សាគោលនយោបាយអប់រំនានា។

តាងនាមអោយវិទ្យាស្ថាន CDRI ខ្ញុំ សូមយកឱកាសនេះ ថ្លែងអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡា ដែលតែងតែផ្តល់កិច្ចសហការយ៉ាងល្អដល់ CDRI។ ជាពិសេស អរគុណ នាយកដ្ឋានគោលនយោបាយ ក្នុងការធ្វើការងារ យ៉ាងជិតស្និត ដើម្បីរៀបចំសន្និសីទនេះឡើង ក៏ដូចជា ការសហការយ៉ាងរលូនទៅលើផ្នែកផ្សេងៗទៀត។ ដូចគ្នានេះផងដែរ ខ្ញុំ ក៏សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) តាមរយៈមូលនិធិអាស៊ី ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់វិទ្យាស្ថាន CDRI ក្នុងការធ្វើការស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យអប់រំ និងរៀបចំសិក្ខាសាលាផ្សេងៗ នាពេលកន្លងមក រួមទាំងពេលនេះផងដែរ។

ជាចុងបញ្ចប់ ខ្ញុំ សូមថ្លែងអំណរគុណដល់វត្តមានរបស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ**ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមសន្និសីទនៅថ្ងៃនេះ ក៏ដូចជាថ្ងៃស្អែកផងដែរ។ ខ្ញុំសូមជូនពរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា** សម្រេចបានជោគជ័យគ្រប់ការងារ និងមានសុភមង្គលក្នុងក្រុមគ្រួសារ។

សូមស្វាគមន៍មកកាន់សន្និសីទគោលនយោបាយអប់រំកម្ពុជាលើកទី៤។

**សូមអរគុណ!**

# បទបង្ហាញគន្លឹះនៃសន្និសីទ



# សិស្សដែលត្រៀមខ្លួន
# រួចរាល់
# សម្រាប់អនាគត៖
# ប្រទេសកម្ពុជា


សាស្ត្រាចារ្យរង David Ng
វិទ្យាស្ថានជាតិអប់រំ
Nanyang Technological University
ប្រទេសសិង្ហបុរី




# ការអប់រំបម្រើទៅលើគោលបំណងដូចខាងក្រោម

## កំណត់ឡើងវិញនូវឧត្តមភាពនៃការបង្រៀន និងរៀន៖ ការត្រៀមខ្លួនសម្រាប់អនាគត

- **ជីវិតការងារ** (lifework)
  (ការងារស្នូលឬសកម្មភាពពេញមួយជីវិតរបស់មនុស្ស)
- **ការរស់នៅ** (living)
  (បទដ្ឋានសង្គម និន្នាការ បញ្ហាប្រឈមផ្នែកបរិស្ថាន)
- **ការរៀន** (learning)
  (ការរៀននាពេលអនាគត៖ រៀនពេញមួយជីវិត (life-long) រៀនទូលំទូលាយ (life-wide) និង រៀនស៊ីជម្រៅ (life-deep)



# គោលបំណងនៃការអប់រំ

## FUTURE-READY LEARNERS BASED ON FOUR DIMENSIONS




Ng, D., Wong, C.P., & Liu, S. (2020). Future-ready Learners: Learning, Lifework, Living, and Habits of Practices. NIE Working Paper Series, 20, 1-86.




Ng, D., Wong, C.P., & Liu, S. (2020). Future-ready Learners: Learning, Lifework, Living, and Habits of Practices. NIE Working Paper Series, 20, 1-86.
National Institute of Education
Nanyang Technological University, Singapore

# និយមន័យនៃការអប់រំឬសាលារៀនដែលជោគជ័យ៖

# ឧទាហរណ៍– តើអ្វីទៅជាជីវិតការងារ (lifework) នាពេលអនាគតរបស់ប្រទេសកម្ពុជា?




Ng, D. F. S. (2019). Defining educational success: The time continuum for leadership learning. Seminar Series 285 Centre for Strategic Education (CSE)

អតីតកាល បច្ចុប្បន្ន អនាគត

# កម្លាំងពលកម្មមានការងារធ្វើនៃប្រទេសកម្ពុជា ចំណែកដោយវិស័យសេដ្ឋកិច្ច (1991-2019)




ផ្នែកសេវាកម្ម (51%)

ផ្នែកកសិកម្ម (26%)

ផ្នែកឧស្សាហកម្ម (23%)

https://data.worldbank.org/indicator/SL.SRV.EMPL.ZS?contextual=employment-by-sector&end=2019&start=1991&view=chart

# កម្មភាពនៃប្រទេសកម្ពុជា ចំណែកដោយវិស័យសេដ្ឋកិច្ច (2021)

| ផ្នែកឧស្សាហកម្ម | ផ្នែកកសិកម្ម | ផ្នែកសេវាកម្ម |
|---|---|---|
| GDP 33% | GDP 25% | GDP 42% |
| កម្លាំងពលកម្ម: 23%  | កម្លាំងពលកម្ម: 26%  | កម្លាំងពលកម្ម: 51%  |

https://www.cia.gov/the-world-factbook/countries/cambodia/#economy



- តើវិស័យការងារនៅកម្ពុជា ទំនងជាមាននិន្នាការយ៉ាងណា ក្នុងរយៈពេល ១០ឆ្នាំ?
- តើអ្នកនឹងអភិវឌ្ឍសិស្សានុសិស្សនៅកម្ពុជាដោយរបៀបណាទៅថ្ងៃអនាគត?
  - សូមលើកឧទាហរណ៍មួយនៃការផ្លាស់ប្តូរក្នុងការបង្រៀន និងរៀន

# ការផ្លាស់ប្តូរដែលមានបែបផែន៖ អភិវឌ្ឍន៍សម្រាប់ការងារជីវិតនាពេលអនាគត

- គម្រោងតាមបែបទំនៀមទំលាប់៖
  - ជំនាញអក្ខរកម្ម
  - ជំនាញលេខ
  - ទិដ្ឋភាពរយៈពេលខ្លី - គោលដៅចុងក្រោយនៃការប្រឡង

- គម្រោងតាមបែបការត្រៀមខ្លួនសម្រាប់អនាគត៖
  - ទិដ្ឋភាពរយៈពេលវែងនៃលទ្ធផលអប់រំ
  - ការច្នៃប្រឌិត
  - ភាពមានជំនាញ

# កំណត់ឡើងវិញនូវគោលបំណងនៃការអប់រំ៖ ការត្រៀមខ្លួននាពេលអនាគតរបស់គ្រូដើម្បីអភិវឌ្ឍសិស្សសម្រាប់ជីវិតការងារ

- ផ្តោតលើការប្រើប្រាស់ជំនាញដែលរួមបញ្ចូល នវានុវត្តន៍ និងការច្នៃប្រឌិត។ បដិវត្តន៍ថ្នាក់រៀនរបស់សិង្ហបុរី - YouTube

- និន្នាការកើនឡើងនៃសេវាកម្មបង្ហាញយ៉ាងច្បាស់ពីសារៈសំខាន់នៃការប្រើប្រាស់ចំណេះដឹងដើម្បីផ្តល់ដំណោះស្រាយ។

- ការកើនឡើងនៃការងារផ្នែកសេវាកម្ម បង្ហាញពីការផ្លាស់ប្តូរពី កត្តាជម្រុញដែលពឹងផ្អែកលើកម្លាំងពលកម្ម និងមូលធន ទៅជាកត្តាជម្រុញនៃចំណេះដឹងសម្រាប់សេដ្ឋកិច្ច។

- សិស្សានុសិស្សគួរតែត្រូវបានលើកទឹកចិត្តឱ្យបង្កើតគំនិត (Ideate)បង្កើតគំរូ (Prototype) និងអនុវត្តភាពជាសហគ្រិនតាមរយៈគម្រោងសាលារៀន

# និយមន័យនៃការអប់រំ ឬសាលារៀនដែលជោគជ័យ៖
# ឧទាហរណ៍– តើអ្វីទៅជា អនាគតនៃការរស់នៅ (Living) ក្នុងប្រទេសកម្ពុជា?




Ng, D. F. S. (2019). Defining educational success: The time continuum for leadership learning. Seminar Series 285 Centre for Strategic Education (CSE)

Not religious
Rights
Individualistic
Euthanasia




Religion
Authority
Family
Marriage

Economic
Physical activities
Less trust

Environmental protection
Gender equality
Participative decision making

Inglehart, R., & Welzel, C. (2010). The WVS cultural map of the world. *World Values Survey*.

# ផែនទីវប្បធម៌

- ***តម្លៃប្រពៃណី*** *(Traditional values)* សង្កត់ធ្ងន់លើសារៈសំខាន់នៃសាសនា ទំនាក់ទំនងរវាងឪពុកម្តាយ និងកូន ការគោរពចំពោះសិទ្ធិអំណាច និងតម្លៃគ្រួសារតាមប្រពៃណីទំនៀមទំលាប់។ មនុស្សដែលប្រកាន់យកតម្លៃទាំងនេះក៏មិនយល់ស្របនឹងការលែងលះ ការរំលូតកូន ការសម្លាប់អ្នកជំងឺដែលមានជំងឺមិនអាចព្យាបាលបានដោយមិនមានការឈឺចាប់ និងការធ្វើអត្តឃាត។ សង្គមទាំងនេះមានមោទនភាពជាតិខ្ពស់ និងមានទស្សនវិស័យជាតិនិយម។
- ***តម្លៃសនិទានភាពដែលមិនមានជំនឿលើសាសនា*** *(Secular-rational values)* មានទំនោរផ្ទុយទៅនឹងតម្លៃប្រពៃណី។ សង្គមទាំងនេះមិនសូវសង្កត់ធ្ងន់លើសាសនា តម្លៃគ្រួសារតាមប្រពៃណីទំនៀមទំលាប់ និងសិទ្ធិអំណាច។ ការលែងលះ ការរំលូតកូន ការសម្លាប់អ្នកជំងឺដែលមានជំងឺមិនអាចព្យាបាលបានដោយមិនមានការឈឺចាប់ និងការធ្វើអត្តឃាតត្រូវបានគេមើលឃើញថាជាទង្វើដែលអាចទទួលយកបាន។ (ប៉ុន្តែមិនមែនមានន័យថាការសម្លាប់ខ្លួនមានភាគរយខ្ពស់ជាងធម្មតាទេ)
- ***តម្លៃរស់រានមានជីវិត*** *(Survival values)* ផ្តោតលើសន្តិសុខសេដ្ឋកិច្ច និងរូបវន្ត។ តម្លៃនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងទស្សនវិស័យជនជាតិភាគតិច និងការជឿទុកចិត្ត និងការអត់ឱននៅកម្រិតទាប។
- ***តម្លៃការបញ្ចេញមតិផ្ទាល់ខ្លួន*** *(Self-expression values)* ផ្តល់អាទិភាពខ្ពស់ដល់ការការពារបរិស្ថាន ការបង្កើនការអត់ឱនចំពោះជនបរទេស មនុស្សដែលស្រលាញ់ភេទដូចគ្នា សមភាពយេនឌ័រ និងការទាមទារនូវការចូលរួមក្នុងការសម្រេចចិត្តក្នុងជីវិតសេដ្ឋកិច្ច និងនយោបាយអោយកាន់តែខ្ពស់។



- តើអ្វីនឹងអាចក្លាយជានិន្នាការនៃផែនទីសង្គមរបស់កម្ពុជាក្នុងរយៈពេល ១០ ឆ្នាំ?
- តើអ្នកនឹងអភិវឌ្ឍសិស្សានុសិស្សនៅកម្ពុជាយ៉ាងណានាថ្ងៃអនាគត?
    - ឧទាហរណ៍នៃការផ្លាស់ប្តូរក្នុងការបង្រៀន និងរៀន

      [https://www.youtube.com/watch?v=mIE5vmZZzZ4](https://www.youtube.com/watch?v=mIE5vmZZzZ4)



# និយមន័យនៃការអប់រំ ឬសាលារៀនដែលជោគជ័យ៖ ឧទាហរណ៍– តើការរស់នៅនាពេលអនាគត ក្នុងប្រទេសកម្ពុជានឹងទៅជាយ៉ាង ណា?




Ng, D. F. S. (2019). Defining educational success: The time continuum for leadership learning. Seminar Series 285 Centre for Strategic Education (CSE)

# ផលប៉ះពាល់ផ្នែកបរិស្ថាន និងគន្លង



- ការកើនឡើងនៃនគរូបនីយកម្មនឹងនាំឱ្យមានការកើនឡើងនៃការប្រើប្រាស់ *:
  - រូបធាតុ (រូបវន្ត ហេដ្ឋារចនាសម្ព័ន្ធ អាហារ ទឹក ។ល។)
  - ថាមពល (អគ្គិសនី ពន្លឺព្រះអាទិត្យ វិសាលគមអេឡិចត្រូម៉ាញ៉េទិច។ល។)

*Ernstson, H., Leeuw, S. E. V. D., Redman, C. L., Meffert, D. J., Davis, G., Alfsen, C., & Elmqvist, T. (2010). Urban transitions: on urban resilience and human-dominated ecosystems. AMBIO: A Journal of the Human Environment, 39(8), 531-545.

# នគរូបនីយកម្មប្រកបដោយនិរន្តរភាព និងការប្រើប្រាស់រូបធាតុនិងថាមពល

ភ្នំពេញ





https://www.pinterest.com/pin/351069733426297745/

## ការប្រើប្រាស់ថាមពលក្នុងប្រទេសកម្ពុជា




https://www.ceicdata.com/en/cambodia/environmental-co2-and-greenhouse-gas-emissions-annual/primary-energy-consumption-per-capita

# នគរូបនីយកម្មប្រកបដោយនិរន្តរភាព និងការប្រើប្រាស់រូបធាតុ និងថាមពល




[ការប្រើប្រាស់ថាមពលនៅកម្ពុជា - តាមប្រភេទឥន្ធនៈ - ក្រាប]

https://aseanenergy.sharepoint.com/PublicationLibrary/Forms/AllItems.aspx?id=%2FPublicationLibrary%2F2020%2FCountry%20Profiles%2FCambodia%2Epdf&parent=%2FPublicationLibrary%2F2020%2FCountry%20Profiles&p=true&ga=1


NIE
An Institute of
NANYANG TECHNOLOGICAL UNIVERSITY SINGAPORE



- តើអ្វីទៅជានិន្នាការសំខាន់បំផុតនៃទិសដៅផ្នែកបរិស្ថានរបស់ប្រទេសកម្ពុជាក្នុងរយៈពេល ១០ឆ្នាំខាងមុខ?
- តើអ្នកនឹងអភិវឌ្ឍអ្នករៀននៅកម្ពុជាទៅជាយ៉ាងណាទៅថ្ងៃអនាគត?
  - សូមលើកឧទាហរណ៍មួយនៃការផ្លាស់ប្តូរក្នុងការបង្រៀន និងរៀន

# ការផ្លាស់ប្តូរដែលមានបែបផែន៖ អភិវឌ្ឍន៍សម្រាប់ការរស់នៅ

- ក្របខណ្ឌប្រពៃណី
  - តម្លៃសង្គម
  - ភាពជាពលរដ្ឋ
- ក្របខណ្ឌការត្រៀមខ្លួននាពេលអនាគត
  - តម្លៃសង្គម
  - ភាពជាពលរដ្ឋ
  - ការរស់នៅប្រកបដោយនិរន្តរភាព

# កំណត់ឡើងវិញនូវគោលបំណងនៃការអប់រំ៖ ការត្រៀមខ្លួននាពេលអនាគតរបស់គ្រូ ដើម្បីអភិវឌ្ឍសិស្សសម្រាប់ការរស់នៅ (living)



- ការសង្កត់ធ្ងន់កាន់តែខ្លាំងលើការអភិវឌ្ឍសិស្សដើម្បីដោះស្រាយការកើនឡើងនៃលទ្ធិនិយម និងតម្លៃការបញ្ចេញមតិផ្ទាល់ខ្លួន
- ជាមួយនឹងនគរូបនីយកម្មកាន់តែរីកធំឡើង ការប្រើប្រាស់រូបធាតុ និងថាមពលកាន់តែច្រើន។
  - ការចូលរួមកាន់តែច្រើននៅក្នុងកិច្ចខិតខំប្រឹងប្រែងប្រកបដោយនិរន្តរភាពទាំងក្នុង និងក្រៅសាលា។
  - សាលារៀនត្រូវតែខិតខំផ្តល់ឱកាសសិក្សាសម្រាប់អ្នករៀនដើម្បីចូលរួមក្នុងការប្រើប្រាស់ធនធានដែលអាចកើតឡើងវិញ និងប្រកបដោយនិរន្តរភាព។ សាលាសិង្ហបូរីណែនាំគំនិតផ្តួចផ្តើមអប់រំអាកាសធាតុ ដើម្បីបង្កើនការយល់ដឹងក្នុងចំណោមសិស្ស - YouTube

# និយមន័យនៃការអប់រំ/សាលារៀនដែលជោគជ័យ៖ ឧទាហរណ៍ តើការរៀននាពេលអនាគតនៅកម្ពុជានឹងទៅជាយ៉ាងណា?




Ng, D. F. S. (2019). Defining educational success: The time continuum for leadership learning. Seminar Series 285 Centre for Strategic Education (CSE)

# Learning poverty and GDP per capita in Asian economies




Note: Bubble size represents population size. Learning poverty is the percentage of children aged about 10 who are unable to read and comprehend a short text appropriate for their age. Data from World Bank (2019).

Source: Newman, Gentile, and dela Cruz, forthcoming.

- https://www.phnompenhpost.com/special-reports/passing-test-cambodias-education-system-failing-its-people

# មជ្ឈមណ្ឌលជីវិត ការរៀនពេញមួយជីវិតនិងការរៀនបែបទំលំទំលាយ៖ ភាពពិតនៃកម្មវិធីសិក្សា




ពេលវេលាប៉ាន់ស្មានដែលបានចំណាយនៅក្នុងសាលារៀន និងបរិយាកាសសិក្សាក្រៅផ្លូវការ។ ចំណាំ៖ ដ្យាក្រាមនេះបង្ហាញពីភាគរយទាក់ទងនៃម៉ោងភ្ញាក់ពីគេងរបស់ពួកគេ ដែលមនុស្សចំណាយពេញមួយជីវិតក្នុងបរិយាកាសអប់រំផ្លូវការ និងសកម្មភាពផ្សេងទៀត។ ការគណនាត្រូវបានធ្វើឡើងតាមស្ថិតិសម្រាប់មូលដ្ឋានពេញមួយឆ្នាំ លើចំនួនពេលវេលាដែលមនុស្សនៅចំណុចផ្សេងៗគ្នាក្នុងអាយុកាលប្រើប្រាស់ក្នុងបរិយាកាសបង្រៀនផ្លូវការ។ រូបភាព និងភាពយន្តត្រូវបានផលិតឡើងវិញដោយមានការអនុញ្ញាតពីមជ្ឈមណ្ឌលជីវិត តាមរយៈ Creative Commons Share Alike License (Stevens, Bransford, & Stevens, 2005)

## ការផ្លាស់ប្តូរដែលមានបែបផែន៖ អភិវឌ្ឍន៍សម្រាប់ការងារជីវិតនាពេលអនាគត

- ក្របខណ្ឌប្រពៃណី
  - កម្មវិធីសិក្សាដែលបានគ្រោងទុក (ផ្លូវការ និងសហកម្មវិធីសិក្សា)

- ក្របខណ្ឌការត្រៀមខ្លួននាពេលអនាគត
  - កម្មវិធីសិក្សាដែលបានគ្រោងទុក
  - ការសិក្សាក្រៅប្រព័ន្ធ (ការរៀនបែបទំលំទំលាយ និងការរៀនបែបស៊ីជម្រៅ)

- បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញសមធម៌ (ធនធាន លទ្ធភាពទទួលបាន និងការសម្រេចបាន)

- ការរៀនបែបសិស្សមជ្ឈមណ្ឌល (student-centered learning) លើចំណុចខ្លាំង និងថាមពលផ្ទាល់ខ្លួន។ https://www.youtube.com/watch?v=tidHA2yZNF0&list=PPSV

- ទទួលយក និងបង្កើតទំនាក់ទំនងរវាងការរៀនពេញមួយជីវិត (ផ្លូវការ) និងការរៀនបែបទំលំទំលាយ (មិនផ្លូវការ)



- ចំណេះដឹងជាគន្លឹះបន្តសម្រាប់នវានុវត្តន៍ ការច្នៃប្រឌិត ការបង្កើតគុណតម្លៃ។
- តើអ្នកនឹងអភិវឌ្ឍសិស្សនៅកម្ពុជាដោយរបៀបណា ដើម្បីសម្រេចបានចំណេះដឹង និងសមត្ថភាពសម្រាប់អនាគត?
  - សូមលើកឧទាហរណ៍មួយនៃការផ្លាស់ប្តូរក្នុងការបង្រៀន និងរៀន

# ឯកសារយោង


- Ng, D., Wong, C.P., & Liu, S. (2020). Future-ready Learners: Learning, Lifework, Living, and Habits of Practices. NIE Working Paper Series, 20, 1-86. (https://entuedu-my.sharepoint.com/:f:/g/personal/fsdng_niestaff_cluster_nie_edu_sg/Eg8vlWtAObNNiXhGWNXhFH8B0HPC30dh3H9hauA4XCmoTw)
- Ng, D. F. S., & Wong, C. P. (2020). The role of school leadership in Singapore's future-ready school reform. *European Journal of Education*, *55*(2), 183-199.
- Ng, D. F. S. (2015). Leadership learning for complex organizations. Cogent Education, 2(1), 1-30.
- Ng, D.F.S. (2013). Assessing Leadership Knowledge in a Principalship Preparation Programme. International Journal of Educational Management, 27(4), 425-445.
- Siemens, G. 2005. Connectivism: A Learning Theory for the Digital Age. 27 International Journal of Technology and Distance Learning, 2, Article 1.

Referenced by the following for transformation of education

1. NIE/NTU where the framework has been endorsed by DSM NIE as part of NIE's future of education framework.
2. NIE and NTU have both referenced the work to inform the new V3SK framework (NIE) and Graduate Attributes in My Learning Navigator (NTU).
3. New South Wales, Australia Association of Independent Schools (AIS) Leadership Centre. Review of flagship leadership programme with referenced from "Defining educational success: The time continuum for leadership learning" (an article based on the future ready learners' framework) The review included a future focused initiative in preparing future ready leaders.
4. Singapore school (Yusof Ishak Secondary) and Singapore Polytechnic adopted future-ready curriculum with referenced to the framework.
5. US Education has published their latest work on the future of education with reference and input from my work. "*The report was published on 5 Dec 2022. Here is the link to the report: The Time is Now (https://www.ncsl.org/education/the-time-is-now)*. The report is endorsed for adoption for all states inUnited States.
6. UN General Assembly. *77th United Nations General Assembly I contributed a chapter in the report: Education Reimagined: Leadership for Transformation - Applying A Global Capabilities Leadership Framework That Informs the Growth of Future Leaders. The chapter is on: Educational Leadership for Future-ready Learning: The Singapore Case. The report was presented at the 77th United Nations General Assembly on 19 Sep 2022 as follows: https://ungaguide.com/event/education-futures education-reimagined/ The case study is in the published work as follows: https://www.wise-qatar.org/education-reimagined-leadership-for-transformation/*
7. The work on future-ready learners is also presented to the World Innovation Submit for Education (WISE) in a short case study - 'A Systems Approach for Future-readiness: Case of Colombia.' The work through WISE on educational transformation will be shared in the United Nations General Assembly in 2024.

អរគុណ



# ការត្រៀមខ្លួនផ្នែកបច្ចេកវិទ្យា ជាគន្លឹះនៃការអប់រំដែលបាន ត្រៀមខ្លួនសម្រាប់អនាគត

*Technology Readiness As a Key to Future-Ready Education*

សុង សុភក្តិ
វិទ្យាស្ថាន CDRI

# មាតិកា

- ការត្រៀមខ្លួនផ្នែកបច្ចេកវិទ្យារបស់សិស្ស
- ការត្រៀមខ្លួនផ្នែកបច្ចេកវិទ្យារបស់គ្រូ
- ទិសដៅបន្ត

# មុខវិជ្ជាដែលសិស្សចូលចិត្ត

| មុខវិជ្ជាណាដែលអ្នកចូលចិត្ត | ប្រុស | ស្រី | វិទ្យាសាស្ត្រសង្គម | វិទ្យាសាស្ត្រពិត | សរុប |
|---|---|---|---|---|---|
| អក្សរសាស្ត្រខ្មែរ | 35% | 38% | 51% | 18% | 37% |
| គណិតវិទ្យា | 22% | 16% | 8% | 33% | 19% |
| ប្រវត្តិវិទ្យា | 10% | 9% | 13% | 5% | 9% |
| រូបវិទ្យា | 7% | 8% | 0% | 18% | 8% |
| ភាសាបរទេស | 5% | 7% | 5% | 7% | 6% |
| សីលធម៌ ពលរដ្ឋវិជ្ជា | 6% | 5% | 8% | 1% | 5% |
| ភូមិវិទ្យា | 5% | 5% | 7% | 1% | 5% |
| គីមីវិទ្យា | 3% | 5% | 0% | 8% | 4% |
| ជីវវិទ្យា | 1% | 4% | 1% | 6% | 3% |
| ផែនដីវិទ្យា/បរិស្ថាន | 1% | 2% | 2% | 1% | 2% |
| បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ | 1% | 1% | 1% | 1% | 1% |
| ផ្សេងៗ | 5% | 2% | 4% | 2% | 3% |
| **សំណាក** | 591 | 864 | 839 | 616 | 1455 |

ប្រភព៖ CDRI និង DoPo (2023)

# ការងារដែលសិស្សចង់ធ្វើនាពេលអនាគត

| ប្រភេទការងារ | ល.រ | ប្រុស | ល.រ | ស្រី | ល.រ | វិទ្យាសាស្ត្រសង្គម | ល.រ | វិទ្យាសាស្ត្រពិត | ល.រ | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| គ្រូបង្រៀន | 6 | 6% | 1 | 21% | 2 | 18% | 2 | 11% | 1 | 15% |
| ប៉ូលីស | 1 | 20% | 3 | 10% | 1 | 21% | 6 | 5% | 2 | 14% |
| គ្រូពេទ្យ / វេជ្ជបណ្ឌិត | 5 | 6% | 2 | 18% | 6 | 4% | 1 | 25% | 3 | 13% |
| មន្ត្រីរាជការ | 2 | 10% | 4 | 6% | 3 | 9% | 5 | 5% | 4 | 7% |
| អ្នកគ្រប់គ្រង | 3 | 7% | 6 | 5% | 5 | 6% | 3 | 6% | 5 | 6% |
| មេធាវី | 8 | 3% | 5 | 6% | 4 | 6% | 9 | 2% | 6 | 5% |
| វិស្វករ | 4 | 7% | 11 | 1% | 8 | 2% | 4 | 6% | 7 | 3% |
| ស្ថាបត្យករ | 9 | 3% | 8 | 2% | 14 | 1% | 6 | 5% | 8 | 3% |
| បុគ្គលិកក្រុមហ៊ុន | 12 | 2% | 7 | 3% | 7 | 3% | 10 | 2% | 9 | 2% |
| អ្នកបង្កើតកម្មវិធីកុំព្យូទ័រ | 7 | 4% | 9 | 1% | 11 | 1% | 8 | 4% | 10 | 2% |
| Youtuber | 11 | 2% | 13 | 1% | 10 | 1% | 13 | 1% | 11 | 1% |
| សហគ្រិន | 14 | 1% | 9 | 1% | 11 | 1% | 11 | 1% | 12 | 1% |
| កីឡាករ | 10 | 3% | 17 | 0% | 8 | 2% | 15 | 1% | 12 | 1% |
| អ្នកសិល្បៈ | 14 | 1% | 11 | 1% | 13 | 1% | 11 | 1% | 14 | 1% |
| អ្នកបើកយន្តហោះ | 13 | 2% | 15 | 0% | 15 | 1% | 13 | 1% | 15 | 1% |
| អ្នកវិទ្យាសាស្ត្រ | 16 | 1% | 14 | 0% | 16 | 0% | 15 | 1% | 16 | 0% |
| អ្នកស្រាវជ្រាវ | 17 | 0% | 15 | 0% | 16 | 0% | 17 | 0% | 17 | 0% |
| ផ្សេងៗ | | 16% | | 14% | | 14% | | 15% | | 15% |
| មិនទាន់ដឹង ឬមិនទាន់សម្រេចចិត្ត | | 10% | | 8% | | 9% | | 7% | | 8% |
| សំណាក | | 591 | | 864 | | 839 | | 616 | | 1455 |

ប្រភព៖ CDRI និង DoPo (2023)

# ជម្រើសជំនាញ និងការផ្លាស់ប្តូរគន្លងសិក្សា

- នៅកម្រិតឧត្តមសិក្សា និស្សិតភាគច្រើន បានជ្រើសរើសមុខជំនាញសិក្សាដែលទាក់ទងនឹងផ្នែកអាជីវកម្ម។
- និស្សិតតិចតួចណាស់ បានជ្រើសរើសមុខវិជ្ជាវិទ្យាសាស្ត្រពិត។
- និស្សិតស្រីដែលស្ថិតក្នុងផ្នែកសិក្សាវិទ្យាសាស្ត្រពិតភាគច្រើន បានប្តូរទៅជំនាញវិទ្យាសាស្ត្រសង្គមវិញនៅពេលពួកគេ ចូលរៀននៅសកលវិទ្យាល័យ។




ប្រភព៖ Ung et al. (2022)

# ការប្រើប្រាស់បច្ចេកវិទ្យារបស់សិស្ស

**គោលបំណងចម្បងក្នុងការប្រើប្រាស់អ៊ីនធឺណិត**

| | ប្រុស | ស្រី | គម្លាត |
|---|---|---|---|
| - រៀន/រៀនជំនាញថ្មី/ការអាន | 38% | 42% | -4% |
| - កម្សាន្ត | 10% | 8% | 2% |
| - ហ្គេម/ហ្គេមអនឡាញ | 3% | 0% | 2% |
| - ទាក់ទងជាមួយមិត្តភក្តិ និងក្រុមគ្រួសារ | 19% | 23% | -3% |
| - ផ្សេងៗ | 30% | 27% | 3% |

ប្រភព៖ អង្កេតសិស្ស

**ការចំណាយពេលជាម៉ោងក្នុងមួយថ្ងៃ**

| | ប្រុស | ស្រី | គម្លាត |
|---|---|---|---|
| - លេងហ្គេម (រួមទាំងអ្នកមិនលេង) | 1.04 | 0.49 | 0.55 |
| - លេងហ្គេម | 1.66 | 1.40 | 0.26 |
| - ប្រើប្រាស់អ៊ីនធឺណិត | 4.31 | 4.19 | 0.11 |
| - Facebook | 1.32 | 1.46 | -0.14 |
| - Telegram | 1.10 | 1.02 | 0.08 |
| - Instagram | 0.50 | 0.60 | -0.10 |
| - TikTok | 1.11 | 0.90 | 0.20 |
| - Line | 0.40 | 0.28 | 0.13 |

ប្រភព៖ អង្កេតសិស្ស

# ការប្រើប្រាស់បច្ចេកវិទ្យារបស់សិស្ស

| | ស្រីច្រើនជាង | មិនខុសគ្នា | ប្រុសច្រើនជាង | មិនដឹង | n |
|---|---|---|---|---|---|
| **លទ្ធផលអង្កេតគ្រូ** | | | | | |
| ការចំណាយពេលក្រៅពីសិក្សាជាមួយមិត្តភក្តិខាងក្រៅ | 33% | 29% | 27% | 12% | 52 |
| ការចំណាយពេលប្រើស្មាតហ្វូនសម្រាប់ការរៀន | 40% | 40% | 13% | 6% | 52 |
| ការចំណាយពេលប្រើស្មាតហ្វូនសម្រាប់ការកម្សាន្ត | 10% | 29% | 52% | 10% | 52 |
| **លទ្ធផលសាលា** | | | | | |
| ការចំណាយពេលក្រៅពីសិក្សាជាមួយមិត្តភក្តិខាងក្រៅ | 15% | 45% | 30% | 10% | 20 |
| ការចំណាយពេលប្រើស្មាតហ្វូនសម្រាប់ការរៀន | 30% | 55% | 10% | 5% | 20 |
| ការចំណាយពេលប្រើស្មាតហ្វូនសម្រាប់ការកម្សាន្ត | 10% | 30% | 45% | 15% | 20 |

ប្រភព៖ អង្កេតគ្រូ និងសាលា

# ចំណាត់ថ្នាក់នៃការត្រៀមខ្លួនផ្នែកបច្ចេកវិទ្យារបស់សិស្ស




ប្រភព៖ Saing et al. (2023)

Explorer៖ មានការលើកទឹកចិត្តខ្ពស់ និងការរារាំងទាប។

Pioneer៖ មានលើកទឹកចិត្តខ្ពស់និងការរារាំងខ្ពស់។

Skeptic ៖ មានការលើកទឹកចិត្តទាប និងការរារាំងទាប។

Hesitator៖ មានការលើកទឹកចិត្តកម្រិតមធ្យម និងការរារាំងខ្ពស់។

Avoider៖ មានការលើកទឹកចិត្តទាប និងការរារាំងខ្ពស់។

# គម្លាតយេនឌ័រ និងតំបន់នៃការត្រៀមខ្លួនផ្នែកបច្ចេកវិទ្យា

| លទ្ធផល | សំណាក់សិស្ស | | |
|---|---|---|---|
| | ប្រុស | ស្រី | ភាពខុសគ្នា |
| TRI score | 3.19 | 3.15 | 0.04*** |
| 1. Explorers | 13.81 | 11.76 | 2.05 |
| 2. Pioneers | 14.11 | 7.74 | 6.37*** |
| 3. Skeptics | 65.62 | 71.73 | -6.11** |
| 4. Hesitators | 4.8 | 4.76 | 0.04 |
| 5. Avoiders | 1.65 | 4.02 | -2.37*** |

ប្រភព៖ Saing et al. (2023)

| លទ្ធផល | សំណាក់សិស្ស | | |
|---|---|---|---|
| | ទីប្រជុំជន (ភ្នំពេញ) | ខេត្ត ឃុំ ជនបទ | ភាពខុសគ្នា |
| TRI score | 3.18 | 3.16 | -0.02 |
| 1. Explorers | 16 | 11.5 | 4.5** |
| 2. Pioneers | 15.5 | 9.1 | 6.4*** |
| 3. Sceptics | 62.2 | 71.3 | -9.1*** |
| 4. Hesitators | 3.7 | 5.2 | -1.5 |
| 5. Avoiders | 2.6 | 2.9 | -0.3 |

ប្រភព៖ Saing et al. (2023)

# កត្តាជះឥទ្ធិពលដល់ការត្រៀមខ្លួនផ្នែកបច្ចេកវិទ្យារបស់សិស្ស

- ភេទ
- សមត្ថភាពភាសាអង់គ្លេស
- ទ្រព្យសម្បត្តិប្រើប្រាស់បានយូរ
- មានថេប្លេតផ្ទាល់ខ្លួន
- បទពិសោធន៍សិក្សាក្នុងថ្នាក់អនឡាញ

***

- សិស្សប្រុស មានទំនោរទៅរកសូចនាករ TRI ខ្ពស់ច្រើនជាងសិស្សស្រី។
- សិស្សដែលសមត្ថភាពភាសាអង់គ្លេសស្ទាត់ជំនាញ មានទំនោរនឹងទទួលបានពិន្ទុ TRI ខ្ពស់ជាងសិស្សដែលមានជំនាញភាសាអង់គ្លេសទាប។

# ការបង្រៀនតាមអនឡាញក្នុងអំឡុងពេលកូវីត១៩

| | ភេទ | | ទីតាំង | | ប្រភេទ | | សរុប |
|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ជនបទ | ទីប្រជុំជន | សាលាទូទៅ | សាលាធនធាន | |
| **ក. មធ្យោបាយនៃការបង្រៀន** | | | | | | | |
| - 100% បង្រៀនតាមonline | 58.2% | 62.2% | 70.7% | 51.4% | 69.1% | 55.6% | 59.9% |
| - 100% បង្រៀនតាមoffline | 36.7% | 29.1% | 26.9% | 38.6% | 27.9% | 36.0% | 33.4% |
| - ការរួមបញ្ចូលគ្នានៃទាំងពីរមធ្យោបាយ | 5.2% | 8.7% | 2.5% | 10.0% | 2.9% | 8.4% | 6.7% |
| ចំនួនអង្កេត | 368 | 275 | 283 | 360 | 204 | 439 | 643 |
| **ខ. វិធីសាស្រ្តបង្រៀនតាមអ៊ីនធឺណិត** | | | | | | | |
| - Synchronous | 22.0% | 23.8% | 15.2% | 28.5% | 15.7% | 26.1% | 22.8% |
| - Asynchronous | 30.7% | 39.1% | 43.7% | 27.4% | 51.0% | 26.7% | 34.4% |
| - វិធីសាស្រ្តទាំងពីរ | 47.3% | 37.0% | 41.2% | 44.1% | 33.3% | 47.2% | 42.8% |
| ចំនួនអង្កេត | 368 | 281 | 277 | 372 | 204 | 445 | 649 |

ប្រភព៖ Chea et al. (2022)

# ឧបករណ៍ និងសេវាកម្មឌីជីថលមានសម្រាប់ប្រើប្រាស់

| | នៅផ្ទះ | | | នៅសាលា | | |
|---|---|---|---|---|---|---|
| | ការប្រើប្រាស់ | មានមធ្យោបាយប្រើប្រាស់* | គ្មានមធ្យោបាយប្រើប្រាស់ | ការប្រើប្រាស់ | មានមធ្យោបាយប្រើប្រាស់* | គ្មានមធ្យោបាយប្រើប្រាស់ |
| កុំព្យូទ័រលើតុ | 6.7% | 3.9% | 89.4% | 9.8% | 74.1% | 16.2% |
| កុំព្យូទ័រយួរដៃ | 42.9% | 8.4% | 48.6% | 2.2% | 37.1% | 60.7% |
| អ៊ីនធឺណែតឥតខ្សែ | 37.3% | 0.7% | 62.0% | 32.3% | 47.9% | 19.8% |
| អ៊ីនធឺណែតទូរស័ព្ទ | 92.1% | 1.3% | 6.6% | 0.0% | 0.0% | 0.0% |
| ទូរស័ព្ទស្មាតហ្វូន | 98.3% | 0.4% | 1.3% | 0.1% | 1.9% | 98.0% |
| ថេប្លេត | 6.3% | 1.9% | 91.8% | 1.7% | 17.0% | 81.2% |
| ម៉ាស៊ីនព្រីន | 16.4% | 2.5% | 81.1% | 31.0% | 60.6% | 8.4% |
| ប្រព័ន្ធរក្សាទិន្នន័យCloud | 32.3% | 3.1% | 64.6% | 4.9% | 20.2% | 74.8% |
| បន្ទប់កុំព្យូទ័រ | - | - | - | 14.0% | 65.4% | 20.7% |
| ឧបករណ៍ថតវិឌីអូ | - | - | - | 3.8% | 32.0% | 64.2% |

*មានមធ្យោបាយប្រើប្រាស់តែមិនបានប្រើប្រាស់ក្នុងកំឡុងខែមុន (តុលា២០២១)
ចំនួនអង្កេតសរុប = 687

ប្រភព៖ Chea et al. (2022)

# ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនអនឡាញ

| | សរុប | ស្រី | ប្រុស | ជនបទ | ទីប្រជុំជន | សាលាទូទៅ | សាលាធនធាន |
|---|---|---|---|---|---|---|---|
| សម្ភារៈឧបទេសថ្មី | 71.1% | 69.6% | 72.2% | 75.2% | 64.1% | 70.0% | 71.5% |
| ការផ្លាស់ប្តូរសម្ភារៈឧបទេស | 53.5% | 38.6% | 63.1% | 35.8% | 62.2% | 34.5% | 59.2% |
| **ថ្នាល** | | | | | | | |
| Google classroom | 70.0% | 66.7% | 72.2% | 75.6% | 66.7% | 66.0% | 71.2% |
| Zoom | 59.6% | 55.0% | 62.7% | 48.1% | 66.3% | 52.0% | 62.0% |
| Telegram | 28.2% | 29.8% | 27.1% | 30.1% | 27.0% | 31.0% | 27.3% |
| Facebook messenger | 17.6% | 16.9% | 18.7% | 26.3% | 12.6% | 20.0% | 16.9% |
| Teams | 9.6% | 12.9% | 7.5% | 5.8% | 11.9% | 8.0% | 10.1% |
| Facebook Live | 2.6% | 1.8% | 3.1% | 2.6% | 2.6% | 2.0% | 2.8% |
| **ចំនួនអង្កេត** | 426 | 171 | 255 | 156 | 270 | 100 | 326 |

ប្រភព៖ Chea et al. (2022)

# ការប្រើប្រាស់បច្ចេកវិទ្យា (គ្រូបង្រៀននៅសាកលវិទ្យាល័យ 2022)




ប្រភព៖ Eam and Song (2023)

# ចំណេះដឹងបច្ចេកវិទ្យាគរុកោសល្យតាមមុខវិទ្យា
Technological Pedagogical Content Knowledge (TPACK)

| | ចំនួននៃធាតុ | ពិន្ទុមធ្យម | គម្លាតស្តង់ដារ | Cronbach Alpha |
|---|---|---|---|---|
| ចំណេះដឹងគរុកោសល្យ (PK) | 5 | 3.92 | 0.36 | 0.65 |
| ចំណេះដឹងតាមមុខវិទ្យា (CK) | 4 | 3.88 | 0.45 | 0.70 |
| ចំណេះដឹងបច្ចេកវិទ្យា (TK) | 5 | 2.87 | 0.69 | 0.82 |
| ចំណេះដឹងគរុកោសល្យតាមមុខវិទ្យា (PCK) | 5 | 4.00 | 0.36 | 0.79 |
| ចំណេះដឹងបច្ចេកវិទ្យាគរុកោសល្យ(TPK) | 4 | 3.55 | 0.63 | 0.77 |
| ចំណេះដឹងបច្ចេកវិទ្យាតាមមុខវិទ្យា (TCK) | 5 | 3.27 | 0.75 | 0.79 |
| ចំណេះដឹងបច្ចេកវិទ្យាគរុកោសល្យតាមមុខវិទ្យា (TPCK) | 5 | 3.39 | 0.73 | 0.88 |
| **សរុប (TPACK)** | **33** | **3.56** | **0.42** | **0.93** |

កំណត់សម្គាល់៖ យកចេញពី Mishra, P., & Koehler, M. J. (2006)

ប្រភព៖ Chea et al. (2022)

# កត្តាជះឥទ្ធិពលដល់ការត្រៀមខ្លួន (គ្រូបង្រៀននៅកម្រិតវិទ្យាល័យ)

| | |
|---|---|
| **កត្តាបុគ្គល**<br>▪ ស្រី (-)<br>▪ អាយុ (-) | **កត្តាបង្រៀន**<br>▪ បង្រៀននៅសាលាឯកជន (+)<br>▪ អន្តរកម្មរវាងគ្រូនិងសិស្ស (+) |
| **បច្ចេកវិទ្យាមានប្រើប្រាស់**<br>▪ កុំព្យូទ័រ (+) | **កត្តាសាលា**<br>▪ ទីតាំងនៅភ្នំពេញ (+)<br>▪ ជាសាលាធនធាន (-) |

# ទិសដៅបន្ត

- ការត្រៀមខ្លួនរបស់សិស្ស ការតំរង់ទិស ការផ្តល់ការពិគ្រោះយោបល់ និងការគាំទ្រផ្សេងទៀត
- ពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀន និងការរៀន
- បញ្ជ្រៀបបច្ចេកវិទ្យាអោយបានស៊ីជម្រៅក្នុងកម្មវិធីកអប់រំ និងអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន
- យកចិត្តទុកដាក់បន្ថែមទៀតចំពោះគម្លាតបច្ចេកវិទ្យាតាមយេនឌ័រ និងតំបន់
- ការពង្រីក និងការប្រើប្រាសធនធានបច្ចេកវិទ្យារបស់សាលាអោយមានប្រសិទ្ធភាព

# សូមអរគុណ!

Cambodia Development Resource Institute

www.cdri.org.kh

## ៩. ខ្លឹមសារសំខាន់ៗនៃវេទិកាពិភាក្សា

ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់នូវធាតុចូលក្នុងការពិភាក្សាសម្រាប់សន្និសីទគោលនយោបាយអប់រំ លើ៩ចំណុចគឺ៖ (១). ការពង្រឹងគុណភាពគ្រឹះស្ថានសិក្សាសាធារណៈ ចាប់ពីថ្នាក់មត្តេយ្យសិក្សាដល់មធ្យមសិក្សា (២). ការអនុវត្តកំណែទម្រង់សាលារៀន (៣). ការអភិវឌ្ឍគ្រូបង្រៀន តាមរយៈកំណែទម្រង់សាលាគរុកោសល្យ (៤). ការពិនិត្យឡើងវិញសៀវភៅសិក្សាគោល និងការកែលម្អវិធីសាស្ត្របង្រៀន (៥). ការលើកកម្ពស់ការអប់រំឌីជីថល (៦). ការអភិវឌ្ឍកម្មវិធីសិក្សា (៧). ការលើកកម្ពស់សុខភាពសិក្សា (៨). ការគាំទ្រសិស្ស និង (៩). ការថែទាំ គាំពារ និងអប់រំកុមារតូច។

### វេទិកាពិភាក្សាទី១៖ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀនល្អ ដើម្បីលើកកម្ពស់លទ្ធផលសិក្សា

ភាពជាអ្នកដឹកនាំមិនត្រឹមតែនៅក្នុងការអប់រំប៉ុណ្ណោះទេ ប៉ុន្តែក្នុងគ្រប់ទិដ្ឋភាព។ ភាពជាអ្នកដឹកនាំគឺជាការរៀនសូត្រ ដែលក្នុងនោះត្រូវមានធាតុបីសំខាន់ (១) សហប្រតិបត្តិការ (Collaboration) (២) ការយល់ស្រប (Consensus) និង (៣) ការសម្រេចចិត្ត (Decision Making) ។ សាលារៀនមួយល្អគឺ ផ្តោតលើភាពជាអ្នកដឹកនាំ ការកសាងធនធានគ្រូបង្រៀន និងអភិបាលកិច្ចសាលារៀន ផ្តល់សិទ្ធអំណាចដល់គ្រូបង្រៀន ការបង្ហាញគោលបំណងរបស់សាលារៀន ដើម្បីកសាងទំនុកចិត្តពីអាណាព្យាបាល ដាក់ទុនវិនិយោគដល់ការសិក្សាកូនៗរបស់ពួកគេ។ កម្មវិធីរៀន និងបង្រៀនពេញមួយថ្ងៃ សិស្សមិនអាចរៀនក្បួរបានទេ គ្រូបង្រៀនបានបំពេញភារកិច្ចពេញលេញនៅសាលារៀន រៀបចំបរិយាកាសអំណោយផលដល់គ្រូបង្រៀន និងសិស្សានុសិស្ស (ឧ. សាលារៀនជំនាន់ថ្មី)។ ទន្ទឹមនឹងនេះបច្ចេកវិទ្យាមានសារៈសំខាន់ណាស់ ហើយត្រូវតែប្រើប្រាស់ក្នុងគ្រប់វិស័យ រួមទាំងរដ្ឋាភិបាល និងសាលារៀនសម្រាប់ការផ្សព្វផ្សាយព័ត៌មាន ការអប់រំ និងជាពិសេសក្នុងការងារអភិបាលកិច្ច។ គ្រប់ប្រព័ន្ធទាំងអស់គឺគួរតែប្រើបច្ចេកវិទ្យាជាពិសេសសាលារៀន ទើបបណ្តុះបណ្តាលពលរដ្ឋឌីជីថល សង្គមឌីជីថល និងរដ្ឋាភិបាលឌីជីថលនាពេលអនាគត។ ការប្រើប្រាស់បច្ចេកវិទ្យាតម្រូវឱ្យមានការប្តេជ្ញាចិត្តក្នុងការប្រើប្រាស់ និងដឹងច្បាស់ពីរបៀបប្រើប្រាស់វា។ ហេតុនេះ ការអភិវឌ្ឍនវិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀន ពិតជាមានសារសំខាន់ខ្លាំងណាស់ជាពិសេសលើផ្នែកបច្ចេកវិទ្យា ដោយផ្តល់អាហារូបករណ៍ បរិយាកាសល្អសម្រាប់ការបង្រៀននិងរៀន មានកម្មវិធីប្រឹក្សាគរុកោសល្យដោយប្រើប្រាស់បច្ចេកវិទ្យា និងមានសម្ភារៈឧបទ្ទេសដែលត្រូវការសម្រាប់ការបង្រៀនដូចជា កុំព្យូទ័រយួរដៃ អ៊ីនធឺណែត ម៉ាស៊ីនបញ្ចាំងស្លាយជាដើម។

### វេទិកាពិភាក្សាទី២៖ ការអភិវឌ្ឍនវិជ្ជាជីវៈជាប្រចាំ តាមរយៈការបង្វឹក និងប្រឹក្សាយោបល់

ការសិក្សាគ្មានទីបញ្ចប់ទេ ត្រូវមានការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ ក្នុងនោះគោលនយោបាយគ្រូបង្រៀន ការទាក់ទាញគ្រូបង្រៀន ការបណ្តុះបណ្តាលដំបូង (Pre-service) និងការបណ្តុះបណ្តាលបន្ត (In-service) ឬការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការធានាសក្តិសិទ្ធភាពការបំពេញការងារ ទាំងគរុនិសិស្សិត គ្រូបង្រៀន និងគ្រូឧទ្ទេសគ្រូសម័យឌីជីថល។ ការបញ្ចូលគ្នានូវគំរូជាច្រើនដូចជា ការប្រឹក្សាយោបល់(Mentoring) ការបង្វឹកដោយផ្ទាល់

(Coaching) បានជួយដោះស្រាយបញ្ហារបស់គ្រូបង្រៀនបានយ៉ាងពិតប្រាកដ បណ្តុះគំនិតខាងក្នុងរបស់គ្រូបង្រៀន(កសាងទម្លាប់) គ្រូបង្រៀនអាចប្រើប្រាស់សមត្ថភាពប្រកបដោយចីរភាព កំណត់ពីបញ្ហាប្រឈមនៃការបង្រៀន និងបង្កើតជាសហគមន៍សិក្សាវិជ្ជាជីវៈជាដើម។

## វេទិកាពិភាក្សាទី៣៖ តើបច្ចេកវិទ្យាជួយកាត់បន្ថយ ឬបង្កើនគម្លាត? តើយើងត្រូវធ្វើដូចម្តេចដើម្បី ប្រើប្រាស់បច្ចេកវិទ្យា ឱ្យបានប្រសើរជាងមុនដើម្បីលើកកម្ពស់ការសិក្សា?

### ១. តួនាទីនៃបច្ចេកវិទ្យាទូទៅដែលរួមចំណែកក្នុងវិស័យអប់រំនិងយុទ្ធសាស្ត្ររាជរដ្ឋាភិបាលកម្ពុជា

បច្ចេកវិទ្យាមានតួនាទី និងមុខងារយ៉ាងសំខាន់ ក្នុងការរួមចំណែកពង្រឹងគុណភាពនៃការផ្តល់សេវាអប់រំ និងបង្កើនឱកាសការងារនាពេលអនាគត។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ទិសដៅយ៉ាងច្បាស់ពីតួនាទីនៃការអប់រំនិងវិទ្យាសាស្ត្រដើម្បីជំរុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គម និងការសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០។ ដើម្បីគាំទ្រដល់ការជំរុញនូវការអនុវត្តនិងប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំ ក្រសួងពាក់ព័ន្ធនានា រួមមាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានសហការជាមួយក្រសួង ស្ថាប័ននានា ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា ដោយបង្កើតឱ្យមាននូវផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាឆ្នាំ២០៣០ ដោយបញ្ជាក់ពីការចូលរួមរបស់បច្ចេកវិទ្យានិងវិទ្យាសាស្ត្រជាគន្លឹះក្នុងការជំរុញសេដ្ឋកិច្ចជាតិតាមរយៈការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សគ្រប់កម្រិតជាពិសេស មុខវិជ្ជាវិទ្យាសាស្ត្រ អក្ខរកម្មឌីជីថល ការត្រៀមខ្លួនរួចរាល់ក្នុងការទទួលនូវបច្ចេកវិទ្យារបស់ពលរដ្ឋ និងការប្រើប្រាស់នូវទិន្នន័យវិទ្យាសាស្ត្រក្នុងការសម្រេចចិត្ត។

### ២. ការរៀបចំប្រព័ន្ធអប់ក្នុងការអភិវឌ្ឍបច្ចេកវិទ្យារបស់ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំនិងដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយមួយចំនួនកន្លងមកក្នុងការអនុវត្តនិងជំរុញបច្ចេកវិទ្យាក្នុងការអប់រំចាប់តាំងពីឆ្នាំ២០០៤ រហូតមកដល់សព្វថ្ងៃ។ ផ្អែកលើគោលនយោបាយទាំងនេះ ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយដៃគូនិងអ្នកពាល់ព័ន្ធនានា ក្នុងការ ១) រៀបចំឧបករណ៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សអាចចូលរៀន ២) ផលិតជាមាតិកាឌីជីថល ការបង្រៀននិងរៀន ដែលស្របនឹងកម្មវិធីសិក្សា ដោយផ្តល់អត្ថប្រយោជន៍ដល់សិស្សអាចរៀនមុនពេលវេលាណាមួយក្រៅម៉ោងសិក្សាបាន ជាពិសេសសិស្សទាំងឡាយណាដែលបាត់បង់ ឱកាសសិក្សា ៣) បង្កើតជាថ្នាល់អប់រំឌីជីថល មានរចនាសម្ព័ន្ធច្បាស់លាស់ ត្រឹមត្រូវ និងងាយស្រួលក្នុងការចូលទៅរកតាមកម្រិតថ្នាក់ និងមុខវិជ្ជា (ឧទាហរណ៍៖ សាលាឌីជីថល ទូរសិក្សា ថ្នាល់អប់រំឌីជីថល) និង ៤) កម្មវិធី E-learning ពិសេសកម្មវិធីធ្វើតេស្តសមត្ថភាពសិក្សាថ្នាក់ទី១២ តាមប្រព័ន្ធអនឡាញ ដែលអាចឱ្យសិស្សចូលទៅវាស់ស្ទង់សមត្ថភាពរបស់ពួកគាត់បាន។

### ៣. ការចូលរួមរបស់វិស័យឯកជនក្នុងការជំរុញបច្ចេកវិទ្យាក្នុងវិស័យអប់រំ

វិស័យអប់រំមិនអាចខ្វះបាននូវការចូលរួមរបស់វិស័យឯកជន។ វិស័យឯកជនមានតួនាទីយ៉ាងសំខាន់មិនអាចខ្វះបានក្នុងការពង្រឹងគុណភាពនៃការអប់រំ ដើម្បីបង្កលក្ខណៈឱ្យអ្នកសិក្សាមានលទ្ធភាពនិងបានប្រើប្រាស់សេវាបានរហ័ស និងពង្រីកវិសាលភាពបន្ថែមគ្របដណ្តប់ដល់អ្នកប្រើប្រាស់សេវានៅតាមតំបន់ជនបទ ដើម្បីបង្រួមគម្លាត និងផ្តល់ឱកាសដល់អ្នកសិក្សានៅតាមតំបន់ជនបទបានប្រើប្រាស់ច្រើន។ បន្ថែមពីនេះ ក្រុមហ៊ុនស្មាតបានសហការជាមួយក្រសួងអប់រំ លើការជំរុញការអប់រំក្រៅប្រព័ន្ធ ដែលក្នុងនោះការធ្វើគម្រោងមួយឈ្មោះ BEEP ដែលសិស្សដែលបញ្ចប់ការសិក្សានឹងទទួលបានជាវិញ្ញាបនបត្រសមមូល ក្នុងនោះអ្នកបាត់បង់ការសិក្សាអាចបន្តការសិក្សាបានតាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យា។

## ៤. ការស្រាវជ្រាវនិងការជំរុញបច្ចេកវិទ្យាក្នុងវិស័យអប់រំជាពិសេសការប្រែប្រួលនៅកម្រិតសាលារៀន

កន្លងមក CDRI បានសហការជាមួយក្រសួងប្រៃសណីយ៍ លើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងក្រសួងអប់រំ យុវជន និងកីឡា លើការត្រៀមខ្លួនរបស់គ្រូបង្រៀនលើការទទួលយកនូវបច្ចេកវិទ្យា (ចំណេះដឹង ជំនាញឬបំណិន និងឥរិយាបថ)។ បើទោះបីជាបច្ចេកវិទ្យាឌីជីថលមានសារសំខាន់ក៏ដោយ ក៏យើងគួរយកចិត្តទុកដាក់លើផលវិបាកដែលកើតចេញពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ជាពិសេសការបង្កើននូវគម្លាតនៃការទទួលបាន និងការប្រើប្រាស់បច្ចេកវិទ្យារវាងអ្នករស់នៅទីក្រុងនិងជនបទ រវាងសិស្សប្រុសនិងសិស្សស្រីជាដើម។ ក្នុងន័យនេះ បច្ចេកវិទ្យាអាចជាអាវុធមុខពីរដែលអាចជួយដល់ការសិក្សា តែក៏អាចបង្កផលអាក្រក់ដល់សិស្សដែរ ប្រសិនបើប្រើប្រាស់មិនត្រូវតាមគោលបំណង។ លើសពីនេះទៀត ក្រសួងអប់រំ យុវជន និងកីឡាគួរ យកចិត្តទុកដាក់លើការអនុវត្តគោលនយោបាយនានាដែលមានស្រាប់ដើម្បីធានាបាននូវលទ្ធផលរឹងនៃគោលនយោបាយទាំងនោះ។

## ៥. ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យត្រូវគោលបំណង

ការជំរុញនូវការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យអប់រំពិតជាមានសារសំខាន់។ ប៉ុន្តែការរំពឹងទុកនិងការអនុវត្តជារឿយៗមិនមានសង្គតិភាពនិងប្រសិទ្ធភាព។ ដើម្បីឱ្យដឹងថាយើងប្រើឱ្យត្រូវគោលបំណង យើងត្រូវយល់ដឹងពីបច្ចេកវិទ្យាជាមុខសិន ថាបច្ចេកវិទ្យាគេប្រើសម្រាប់អ្វី។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាកត្តាសម្រួលការអនុវត្ត(ស្ពាន)ជាជាងកត្តាតែមួយគត់ឬកត្តាកំណត់គុណភាពបង្រៀននិងរៀន។ ដូច្នេះ អ្នកសិក្សាត្រូវស្វែងយល់ពីបច្ចេកវិទ្យាឱ្យបានច្បាស់លាស់សិន ទើបយើងអាចប្រើប្រាស់ទៅចំគោលបំណង និងដោយផ្សារភ្ជាប់ជាមួយនឹងការតាមដាននិងវាយតម្លៃឱ្យបានទៀងទាត់។ ប្រសិនបើមិនមាននូវក្របខណ្ឌគតិយុត្តច្បាស់លាស់ នោះការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលអាចផ្តល់នូវភាពរំខាន និងបង្អាក់វឌ្ឍនភាពនៃការជំរុញកម្មវិធីកំណែទម្រង់វិស័យអប់រំផងដែរ។ ក្រសួងពាក់ព័ន្ធបាននិងកំពុងគិតពីការរៀបចំក្របខណ្ឌជាតិលើការប្រើប្រាស់នូវបញ្ញាសិប្បនិម្មិត (AI) ក្នុងការបង្រៀននិងរៀនសម្រាប់ប្រើប្រាស់នៅប្រទេសកម្ពុជា ដើម្បីបង្កើននូវទំនួលខុសត្រូវនិងជៀសវាងភាពអណាធិបតេយ្យនិងផលវិបាកនានា។

## ៦. ប្រព័ន្ធគ្រប់គ្រងការបង្រៀននិងរៀន

បច្ចេកវិទ្យាឌីជីថលត្រូវបានបញ្ជ្រាបចូលមកក្នុងវិស័យអប់រំជាច្រើនឆ្នាំមកហើយ។ គុណភាពនៃការអប់រំអាស្រ័យលើសមត្ថភាពក្នុងការចាប់យកនូវផលប្រយោជន៍នានាចេញពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ក្នុងន័យនេះ ប្រសិនបើអ្នកពាក់ព័ន្ធមិនចេះចាប់យកនូវផលប្រយោជន៍នានារបស់បច្ចេកវិទ្យាឌីជីថលនោះទេ នោះគេអាចនឹងបាត់បង់ផលចំណេញនានាដល់វិស័យនានា ជាពិសេសសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។ លើសពីនេះ នៅពេលបច្ចេកវិទ្យាចូលមកហើយ តែមិនមានសមត្ថភាពប្រើប្រាស់និងការប្រើប្រាស់ទៀតសោតមិនតាមគោលបំណង អាចនាំគ្រោះថ្នាក់ដល់យើងជាអ្នកប្រើប្រាស់ (ឧទាហរណ៍ ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ជំនួយការរៀននិងបង្រៀនពុំត្រឹមត្រូវ)។ នៅពេលបច្ចេកវិទ្យាចូលមកហើយ តែមិនយល់ពីវានោះយើងអាចនឹងមានគ្រោះថ្នាក់ តាមរយៈចែករំលែកបន្តដោយពុំដឹងពីព័ត៌មានពិតឬមិនពិត ដែលសុទ្ធសឹងតែបង្កនូវគ្រោះ ថ្នាក់។ បន្ថែមពីនេះ ដើម្បីត្រៀមខ្លួនក្នុងការអនុវត្តបច្ចេកវិទ្យាឌីជីថលមានប្រសិទ្ធភាព ក្រសួងអប់រំបានគិតគូរនិងធ្វើមួយជំហានមុន ដោយបានបញ្ចូលក្រមសីលធម៌ និងការទទួលខុសត្រូវរបស់អ្នកប្រើប្រាស់បច្ចេកវិទ្យាឱ្យបានយល់ដឹងត្រឹមត្រូវតាមរយៈការបញ្ចូលទៅក្នុងក្របខណ្ឌកម្មវិធីសិក្សាចាប់ពីថ្នាក់ទី៤ ដល់ទី១២។ អ្វីដែលសំខាន់ជាងនេះគឺ ការលើកកម្ពស់ការយល់ដឹងរបស់អ្នកប្រើប្រាស់គ្រប់កម្រិតឱ្យយល់ច្បាស់ពីភាពអវិជ្ជមាននៃបច្ចេកវិទ្យា

ឪដីថល ក្នុងការធានានូវសុវត្ថិភាព និងពិចារណាលើការកំណត់វ័យឬកម្រិតថ្នាក់ក្នុងការប្រើប្រាស់ឪដីថល ដើម្បីកុំឱ្យប៉ះពាល់ និងកាត់បន្ថយផលអវិជ្ជមាន។

**វេទិកាពិភាក្សាទី៤៖ ឧត្តមានុវត្តន៍ ភាពជាដៃគូរវាងសាធារណៈ និងសហគមន៍**

សហគមន៍គឺ ជាម្ចាស់របស់សាលារៀន និងជាអតិថិជនរបស់សាលារៀន។ ការមានសមត្ថភាពអ្នកដឹកនាំ និងទំនាក់ទំនងល្អជាមួយ គ្រូបង្រៀន និងសហគមន៍ នោះលទ្ធផលសិក្សារបស់សិស្សនឹងកាន់តែល្អប្រសើរ តាមរយៈដំណាក់កាលទាំង៥រួមមាន (១) ធ្វើតេស្តស្តង់ដា (ហៅឪពុកម្តាយមកមើល) (២) វាយតម្លៃលទ្ធផលតេស្ត (សិស្សធ្វើផែនការរៀនខ្លួនឯង គាត់ជាអ្នកកំណត់ខ្លួនឯង) (៣) ធ្វើកិច្ចព្រមព្រៀងជាមួយមាតាបិតានិងគ្រូ (៤) អនុវត្ត និង (៥) ពិនិត្យតាមដាន។

ច្បាប់រដ្ឋធម្មនុញ្ញ មាត្រា៣៥ និងច្បាប់ការអប់រំ មាត្រាទី៤៤ ឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមក្នុងវិស័យអប់រំ។ ច្បាប់កម្ពុជាចែងថា ប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសិទ្ធិចូលរួមគ្រប់សកម្មភាពក្នុងបរិបទសេដ្ឋកិច្ច សង្គម និងនយោបាយ។ សាលារៀនត្រូវអនុវត្តតាមសេចក្តីណែនាំ ស្តីពីការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន(គគស)។ គគស ត្រូវបានជ្រើសរើសដោយបោះឆ្នោត និងមានការប្រជុំជាទៀតទាត់។ ការចូលរួមរបស់សហគមន៍រួមមាន ពេលវេលា ចំណេះដឹង សម្ភារ និងថវិកា។ សមាជិក គគស. ត្រូវមានឆន្ទៈនិងការលះបង់ និងការពេញចិត្តធ្វើយ៉ាងពិតប្រាកដ ក្នុងការធ្វើផែនការប្រមូលមូលនិធិពីអ្នកមានធនធាន និងអ្នកមានឋានៈ ដើម្បីចូលរួមធ្វើឱ្យសាលារៀនមានការអភិវឌ្ឍ។ ការគាំទ្រពីសហគមន៍ពិតជាមានសារៈសំខាន់ ជាពិសេសការគាំទ្រផ្នែកហិរញ្ញវត្ថុ។ ការបង្កើត គគស សហគមន៍និងសាលារៀន អាចពឹងផ្អែកគ្នាទៅវិញទៅមក ប្រៀបដូចទឹកនិងត្រី ។

បច្ចុប្បន្នមានសាលារៀនជាច្រើនបានបង្កើតជាមូលនិធិសមធម៌ (ប្រហែល ៧០ សាលា) ដោយមានការចូលបដិភាគតាមគោលការណ៍ស្ម័គ្រចិត្ត មានន័យថាមនុស្សគ្រប់រូបនៅក្នុងសហគមន៍អាចចូលរួមកម្មវិធីនេះដោយសេរី និងបរិច្ចាគតាមដែលពួកគេចង់ដើម្បីធានាប្រសិទ្ធភាព និងគុណភាពនៃការអប់រំ។ ទន្ទឹមនឹងនេះ មូលនិធិសមធម៌ជំរុញការអនុវត្តការរៀនពេញមួយថ្ងៃ កម្មវិធីសិក្សាទំនើប ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល ដោយបុគ្គលិកអប់រំទទួលការលើកទឹកចិត្តជាប្រាក់ឧបត្ថម្ភ និងឪពុកម្តាយសប្បាយចិត្តដែលកូនបានរៀនមួយវេនទៀត។ បច្ចុប្បន្ន ដើម្បីទទួលបានកិច្ចសហការល្អរវាងសហគមន៍និងសាលារៀនការសាលារៀនគួរធ្វើសកម្មភាពមួយចំនួន ជាពិសេសតាមរយៈបណ្តាញសង្គមដូចជា(១) ផ្តល់ពេលវេលា ទំនាក់ទំនងល្អជាមួយសហគមន៍ (២)មានតម្លាភាពនិងគណនេយ្យភាព (ចង់ជោគជ័យខាងក្រៅ ធ្វើខាងក្នុងឲ្យជោគជ័យ) (៣) បង្ហាញលទ្ធផល (ធ្វើឲ្យគេជឿ ត្រូវបង្កើតលទ្ធផលឲ្យគេឃើញ) (៤) យកចិត្តទុកដាក់លើសុខមាលភាពរបស់សិស្សានុសិស្ស (ធ្វើយ៉ាងមិច ឱ្យសិស្សនិយាយល្អពីសាលារៀន គ្រូ បង្កើតការជឿទុកចិត្តរវាងឪពុកម្តាយ និងគ្រូ និងកែលម្អការអនុវត្តរបស់សិស្ស ដូច្នេះពួកគេសុខចិត្តគាំទ្រ និងលះបង់តាមការស្នើសុំរបស់សាលា)។

**១០.អនុសាសន៍ និងមតិបិទសន្និសីទគោលនយោបាយអប់រំ លើកទី៤**

**ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីបានផ្តល់នូវធាតុចូលក្នុងការពិភាក្សាសម្រាប់សន្និសីទគោលនយោបាយអប់រំលើ ៩ចំណុចគឺ៖**

(១). ការពង្រឹងគុណភាពគ្រឹះស្ថានសិក្សាសាធារណៈ ចាប់ពីថ្នាក់មត្តេយ្យសិក្សាដល់មធ្យមសិក្សា (២). ការអនុវត្តកំណែទម្រង់សាលារៀន (៣). ការអភិវឌ្ឍគ្រូបង្រៀន តាមរយៈកំណែទម្រង់សាលាគរុកោសល្យ (៤). ការពិនិត្យឡើងវិញសៀវភៅសិក្សាគោល និងការកែលម្អវិធីសាស្ត្របង្រៀន (៥). ការលើកកម្ពស់ការអប់រំឌីជីថល (៦). ការអភិវឌ្ឍកម្មវិធីសិក្សា (៧). ការលើកកម្ពស់សុខភាពសិក្សា (៨). ការគាំទ្រសិស្ស និង (៩). ការថែទាំ គាំពារ និងអប់រំកុមារតូច។

## ដំណើរការពិភាក្សា

**វេទិកាទី១៖ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀនល្អ ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស**

- ប្រព័ន្ធទាំងអស់គឺត្រូវប្រើបច្ចេកវិទ្យាជាពិសេសសាលារៀន ទើបអាចខ្លាយទៅជាសង្គមឌីជីថល

- ភាពជាអ្នកដឹកនាំរបស់សាលារៀន គឺជាការគ្រប់គ្រង គ្រប់គ្រងបុគ្គលិក គ្រប់គ្រងពេលវេលា

-ការទទួលស្គាល់ភាពខ្សោយ (កំហុស) របស់ខ្លួនឯង ដើម្បីរៀនចំណុចខ្លាំងពីមនុស្សពូកែ

-ភាពជាអ្នកដឹកនាំត្រូវមាន សហប្រតិបត្តិការ (Collaboration) ការយល់ស្រប (Consensus) និងការសម្រេចចិត្ត (Decision Making)

-កម្មវិធីរៀនពេញមួយថ្ងៃ សិស្សមិនអាចរៀនកួរទេ គ្រូបង្រៀនបានបំពេញភារកិច្ចពេញលេញ

-នៅសាលារៀន រៀបចំបរិយាកាសអំណោយផលដល់គ្រូបង្រៀន និងសិស្សានុសិស្ស (សាលារៀនជំនាន់ថ្មី)

-សាលារៀនមួយល្អគឺ ផ្តោតលើភាពជាអ្នកដឹកនាំ ការកសាងធនធានគ្រូបង្រៀន និងអភិបាលកិច្ចសាលារៀន

-ផ្តល់សិទ្ធអំណាចដល់គ្រូបង្រៀន ការបង្ហាញគោលបំណងរបស់សាលា ដើម្បីកសាងទំនុកចិត្តពីអាណាព្យាបាល ដាក់ទុនវិនិយោគ

**វេទិកាទី២៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ តាមរយៈការបង្វឹក និងប្រឹក្សាយោបល់**

- គោលនយោបាយគ្រូបង្រៀន ការទាក់ទាញគ្រូបង្រៀន ការបណ្តុះបណ្តាលដំបូង ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការជានាសក្តិសិទ្ធភាពការបំពេញការងារ ទាំងគរុនិសិស្សិត និងគ្រូឧទ្ទេស

- គ្រូសម័យឌីជីថល ត្រូវចេះអភិវឌ្ឍសមត្ថភាពខ្លួនឯង និងចេះផ្តល់ចំណេះដឹងដល់សិស្ស

- ទម្រង់បំប៉នបន្តដល់គ្រូបង្រៀន ពីអ្នកជំនាញទៅមន្ត្រីបង្គោល ដើម្បីអាចបំប៉នបន្ត (Cascade)

- ការផ្តល់ប្រឹក្សាគរុកោសល្យ (Mentoring)

- ការជួយដោយផ្ទាល់ (Coaching)

- ត្រូវប្រាកដថាបានជួយដោះស្រាយបញ្ហារបស់គ្រូពិតប្រាកដ ទើបគ្រូអាចយកទៅប្រើប្រាស់បន្តទៀត

- ដើម្បីឱ្យមានចីរភាព បណ្ដុះគំនិតខាងក្នុងរបស់គ្រូ ជាអ្វីដែលគ្រូបង្រៀនខិតខំដោយខ្លួនឯង

- ការរៀបចំសិក្ខាសាលាសម្រាប់គ្រូ កំណត់ពីបញ្ហានៃការបង្រៀន និងបង្កើតជាសហគមន៍សិក្សាវិជ្ជាជីវៈ

**វេទិកាទី៣៖ តើបច្ចេកវិទ្យាជួយកាត់បន្ថយឬបង្កើនគម្លាត? តើយើងត្រូវធ្វើដូចម្ដេចដើម្បីប្រើប្រាស់បច្ចេកវិទ្យាឱ្យបានប្រសើរជាងមុនក្នុងការលើកកម្ពស់ការសិក្សា?**

**- ផែនទីបង្ហាញផ្លូវឆ្នាំ២០២៣ បច្ចេកវិទ្យាក្នុងវិស័យអប់រំ គឺត្រូវការប្រព័ន្ធគ្រប់គ្រងទិន្នន័យ**

- គោលនយោបាយ ICT សម្រាប់ការអប់រំ ឆ្នាំ២០០៤ ជាបន្តបន្ទាប់ ដល់២០១៨ ធ្វើទំនើបកម្ម ២០២៣ ធ្វើយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន

- ការបង្កើតថ្នាលអប់រំឌីជីថល និងមាតិកាឌីជីថល

- ការពង្រឹងគុណភាពសេវាអ៊ីនធឺណេត សេវាគ្រួបដណ្ដប់ ដើម្បីឱ្យកម្មវិធីដំណើរការបានល្អ

- Content, Connectivity, Electricity, កង្វះខាត គឺជាឧបសគ្គនៃការប្រើបច្ចេកវិទ្យា

- ការកំណត់សុវត្ថិភាពកម្រិតជាតិ ការបញ្ចូលក្រមសីលធម៌ក្នុងការប្រើបច្ចេកវិទ្យា

- បង្កើនកម្មវិធីអក្ខរកម្មឌីជីថល ចំណេះដឹងលើការវិភាគព័ត៌មាន ការប្រើប្រាស់ Generative AI

**វេទិកាទី៤៖ ឧត្តមានុវត្តន៍នៃភាពជាដៃគូសាធារណៈ និងសហគមន៍**

- ការចូលរួមរបស់សហគមន៍គឺជាផ្នែកមួយធំបំផុតក្នុងការអភិវឌ្ឍសាលារៀន

- ការបង្កើតមូលនិធិសមធម៌ (បដិភាគ តាមគោលការណ៍ស្ម័គ្រចិត្ត) សម្រាប់ការអប់រំ

- ភាពជាដៃគូសាលារៀន និងសហគមន៍៖ ១. ធ្វើតេស្តស្ដង់ដា ២. ធ្វើផែនការរៀន ៣. ធ្វើកិច្ចព្រមព្រៀង ៤. គណៈកម្មការដឹងលឺ ៥. មាតាបិតាចូលរួម

- សហគមន៍គឺជាអតិថិជនរបស់សាលារៀន ជាម្ចាស់របស់សាលារៀន

- មានទំនាក់ទំនងល្អជាមួយសហគមន៍ បង្កើតសមត្ថភាពអ្នកដឹកនាំនិងគ្រូបង្រៀន លទ្ធផលសិក្សាល្អ

- ត្រូវមានកិច្ចសន្យា បង្កើតគណៈកម្មការថ្នាក់រៀន

## ១១.មតិគន្លឹះ និងសារសំខាន់ៗ

- ផ្តល់សេវាអប់រំ ឱ្យធ្វើដូចអ្នកលក់ និងអ្នកទិញ
- ប្រសិទ្ធភាពនៃភាពអ្នកដឹកនាំ ត្រូវមានចក្ខុវិស័យ បេសកកម្ម គោលដៅ ច្បាស់លាស់
- គណនេយ្យភាពរបស់សាលារៀនគឺជាចំណុចសំខាន់បំផុត
- ត្រូវមើលខ្លួនឯងមុន ដើរតាមភាពជោគជ័យរបស់អ្នកដទៃ
- ការសិក្សាគ្មានទីបញ្ចប់ទេ ត្រូវមានការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ
- ការបញ្ចូលគ្នានូវម៉ូដែលជាច្រើនបញ្ចូលគ្នា **Metoring, Coaching,**
- ការប្រើពេលវេលាឱ្យបានត្រឹមត្រូវ ពេលវេលាគិត សម្រាប់គ្រូ ការបង្រៀន
- ធ្វើខ្លួនឱ្យក្លាយជាបុគ្គលដែលរៀនពេញមួយជីវិត (បណ្តុះទម្លាប់)
- ស្វែងរកកត្តាណាដែលជំរុញលើកទឹកចិត្តដោយខ្លួនឯងក្នុងការធ្វើជាគ្រូបង្រៀន
- បច្ចេកវិទ្យាជាអាវុធមុខ២ ៖ ការប្រើសម្រាប់គាំទ្រដល់គោលបំណងក្នុងការរៀនសូត្របានត្រឹមត្រូវ
- ការប្រើចំណេះដឹងបច្ចេកវិទ្យាជាប្រយោជន៍សម្រាប់អ្នកដទៃនិងស្ថាប័ន
- សហគមន៍ និងសាលារៀន ប្រៀបបានដូចជា ទឹក និងត្រី ត្រូវការគ្នា បំពេញឱ្យគ្នាទៅវិញទៅមក
- ដាច់ខាតត្រូវមានទំនាក់ទំនងល្អជាមួយសហគមន៍ តម្លាភាព និងគណនេយ្យភាពខាងក្នុង ធ្វើកិច្ចការឱ្យជោគជ័យដោយមានការសហការចូលរួមពីសហគមន៍
- លទ្ធផលដែលគេជឿជាក់បាន
- គិតគូរពីសុខុមាលភាពរបស់កុមារ
- ឱ្យសិស្សទៅផ្ទះវិញអួតពីសាលារៀនពីគ្រូ
- អំណាចនៃការផ្លាស់ប្តូរដ៏ល្អបំផុត គឺធ្វើឱ្យសហគមន៍យល់ដឹង
- សាលារៀនដើរតួយ៉ាងសំខាន់ក្នុងការកសាងពលរដ្ឋល្អ ដូច្នេះសាលារៀនត្រូវមានទាំងអ្នកដឹកនាំល្អ និងគ្រូបង្រៀនល្អ
-មានចក្ខុវិស័យ និងគោលដៅច្បាស់លាស់ និងការងាររដ្ឋបាលប្រកបដោយប្រសិទ្ធភាព ដែលជួយសម្រួលដល់លំហូរនៃការងារ ។
- គ្រូបង្រៀនត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងស្រឡាញ់ការបង្រៀនរបស់ពួកគេនឹងត្រូវបានលើកទឹកចិត្តឱ្យចូលរួម មានភាពជាម្ចាស់នៃ និងមានការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។
- ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីសម្រួលដល់ការងារដឹកនាំ ការគ្រប់គ្រងរដ្ឋបាល ការបង្រៀន និងសកម្មភាពសិក្សា
- សហគមន៍គួរតែចូលរួម និងលើកទឹកចិត្តឱ្យធ្វើជាម្ចាស់នៃការគ្រប់គ្រងសាលារៀន
- សាលារៀនគួរផ្សារភ្ជាប់ទំនាក់ទំនង និងកសាងទំនុកចិត្តជាមួយឪពុកម្តាយ ដោយបង្ហាញពីរបៀបដែលពួកគេយកចិត្តទុកដាក់ចំពោះសិស្ស ដែលអាចឆក់យកបេះដូងសហគមន៍។

## .ឧបសម្ព័ន្ធ

## ១២.១.ឧបសម្ព័ន្ធទី១៖ លិខិតស្នើសុំចាត់សមាសភាពចូលរួមសន្និសីទគោលនយោបាយអប់រំ លើកទី៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា
លេខ:១១៣៩ អយក.កប

ថ្ងៃអង្គារ ១០កើត ខែ ផល្គុន ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ មីនា ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**សូមគោរពជូន**
**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**កម្មវត្ថុ៖** សំណើសុំចាត់តំណាងចំនួន ១រូប ដើម្បីចូលរួមក្នុងសន្និសីទគោលនយោបាយអប់រំ ស្តីពី **"ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និង ធានាគុណភាពអប់រំ"** ។

**យោង៖** ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ៖ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និង អង្គការវេទិកាអនាគត (Future Forum) ដើម្បីរៀបចំសន្និសីទគោលនយោបាយអប់រំ ស្តីពី "ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និង ធានាគុណភាពអប់រំ" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី **២០-២១ ខែ មីនា ឆ្នាំ២០២៤** នៅ **វិទ្យាស្ថានជាតិអប់រំ** ។ សន្និសីទនេះ មានគោលបំណង៖ ១) ពិនិត្យមើលវឌ្ឍនភាព និង បញ្ហាប្រឈម ក្នុងកំណែទម្រង់សាលារៀន ការចូលរួមរបស់សហគមន៍ និង ការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ២) នវានុវត្តន៍ក្នុងការអប់រំ ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដែលអាចជួយដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើង កសាងភាពធន់នៃប្រព័ន្ធអប់រំ និង ចែករំលែកឧត្តមានុវត្តន៍នៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំ និង ៣) សម្របសម្រួលកិច្ចសហការ រវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និង គ្រប់ភាគីពាក់ព័ន្ធ ក្នុងការស្រាវជ្រាវវិស័យអប់រំ ដោយកំណត់ប្រធានបទស្រាវជ្រាវដែលមានសក្តានុពល ដើម្បីរួមចំណែកក្នុងការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង និង លើកកម្ពស់គុណភាពនៃការស្រាវជ្រាវអប់រំនៅកម្ពុជា ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាចាត់តំណាងក្រសួងមុខងារសាធារណៈ ចំនួន ១ រូប ដើម្បីចូលរួមក្នុងសន្និសីទគោលនយោបាយអប់រំនេះ តាមកម្មវិធីដូចមានភ្ជាប់ ដោយសេចក្តីអនុគ្រោះ ។

សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** មេត្តាទទួលនូវការគោរពដ៏ស្មោះពីខ្ញុំ ។

**រដ្ឋមន្ត្រីស្តីទី**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានគោលនយោបាយ

**សូមមេត្តាផ្តល់ព័ត៌មានតាមរយៈតេលេក្រាមលេខ៖ 012 464 030**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១១៣៧ អយក.កប

ថ្ងៃអង្គារ ១០កើត ខែមឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**គោរពជូន**
**ឯកឧត្តម ពេជ សោភ័ន ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា**

**កម្មវត្ថុ៖** សំណើសុំចាត់តំណាងចំនួន ១ រូប ដើម្បីចូលរួមក្នុងសន្និសីទគោលនយោបាយអប់រំ ស្តីពី **"ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និង ធានាគុណភាពអប់រំ"** ។

**យោង៖** ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា ៖ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និង អង្គការវេទិកាអនាគត (Future Forum) ដើម្បីរៀបចំសន្និសីទគោលនយោបាយអប់រំ ស្តីពី "ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និង ធានាគុណភាពអប់រំ" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី **២០-២១** ខែ **មីនា ឆ្នាំ២០២៤** នៅ **វិទ្យាស្ថានជាតិអប់រំ** ។ សន្និសីទនេះ មានគោលបំណង៖ **១)** ពិនិត្យមើលវឌ្ឍនភាព និង បញ្ហាប្រឈម ក្នុងកំណែទម្រង់សាលារៀន ការចូលរួមរបស់សហគមន៍ និង ការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស **២)** នវានុវត្តន៍ក្នុងការអប់រំ ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដែលអាចជួយដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើង កសាងភាពធន់នៃប្រព័ន្ធអប់រំ និង ចែករំលែកឧត្តមានុវត្តន៍នៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំ និង **៣)** សម្របសម្រួលកិច្ចសហការរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និង គ្រប់ភាគីពាក់ព័ន្ធ ក្នុងការស្រាវជ្រាវវិស័យអប់រំ ដោយកំណត់ប្រធានបទស្រាវជ្រាវដែលមានសក្តានុពល ដើម្បីរួមចំណែកក្នុងការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង និង លើកកម្ពស់គុណភាពនៃការស្រាវជ្រាវអប់រំនៅកម្ពុជា ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាចាត់តំណាង ចំនួន ១ រូប ដើម្បីចូលរួមក្នុងសន្និសីទគោលនយោបាយអប់រំនេះ តាមកម្មវិធីដូចមានជូនភ្ជាប់ តាមការគួរ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ** ។

**រដ្ឋមន្ត្រីស្តីទី**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានគោលនយោបាយ

**សូមមេត្តាផ្តល់ព័ត៌មានតាមរយៈតេលេក្រាមលេខ៖** 012 464 030

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ១១៣៤ អយក.គប

ថ្ងៃអង្គារ ១០កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**គោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**កម្មវត្ថុ៖** សំណើសុំចាត់តំណាងចូលរួមចំនួន ១ រូប និង ធ្វើជាវាគ្មិន ចំនួន ១ រូប ក្នុងសន្និសីទគោលនយោបាយអប់រំ ស្ដីពី **"ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និង ធានាគុណភាពអប់រំ"** ។

**យោង៖** ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម រដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និង អង្គការវេទិកាអនាគត (Future Forum) ដើម្បីរៀបចំសន្និសីទគោលនយោបាយអប់រំ ស្ដីពី "ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និង ធានាគុណភាពអប់រំ" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី **២០-២១ ខែ មីនា ឆ្នាំ២០២៤** នៅ **វិទ្យាស្ថានជាតិអប់រំ** ។ សន្និសីទនេះ មានគោលបំណង៖ ១) ពិនិត្យមើលវឌ្ឍនភាព និង បញ្ហាប្រឈម ក្នុងកំណែទម្រង់សាលារៀន ការចូលរួមរបស់សហគមន៍ និង ការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ២) នវានុវត្តន៍ក្នុងការអប់រំដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដែលអាចជួយដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើង កសាងភាពធន់នៃប្រព័ន្ធអប់រំ និង ចែករំលែកឧត្តមានុវត្តន៍នៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំ និង ៣) សម្របសម្រួលកិច្ចសហការ រវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និង គ្រប់ភាគីពាក់ព័ន្ធ ក្នុងការស្រាវជ្រាវវិស័យអប់រំ ដោយកំណត់ប្រធានបទស្រាវជ្រាវដែលមានសក្តានុពល ដើម្បីរួមចំណែកក្នុងការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង និង លើកកម្ពស់គុណភាពនៃការស្រាវជ្រាវអប់រំនៅកម្ពុជា ។

សេចក្តីដូចបានម្រាបជូនខាងលើ សូម **ឯកឧត្តម រដ្ឋមន្ត្រី** ចាត់មន្ត្រីជំនាញចូលរួម និង ធ្វើជាវាគ្មិនក្នុងសន្និសីទគោលនយោបាយអប់រំនេះ តាមប្រធានបទដូចមានក្នុងតារាងជូនភ្ជាប់ តាមការគួរ ។

សូម **ឯកឧត្តម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ទទួលនូវគោរពកិច្ចដ៏ស្មោះពីខ្ញុំ ។

**រដ្ឋមន្ត្រីស្ដីទី**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានគោលនយោបាយ

**សូមមេត្តាផ្តល់ព័ត៌មានតាមរយៈតេលេក្រាមលេខ៖ 012 464 030**

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១១៤០ អយក.គប

ថ្ងៃអង្គារ ១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**គោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**កម្មវត្ថុ៖** សំណើសុំចាត់តំណាងចំនួន ១ រូប ដើម្បីធ្វើជាវាគ្មិន ក្នុងសន្និសីទគោលនយោបាយអប់រំ ស្តីពី "**ដំណើរឆ្ពោះទៅការត្រៀមខ្លួនរបស់សាលារៀននាពេលអនាគតដើម្បីកសាងភាពធន់ និង ធានាគុណភាពអប់រំ**" ។

**យោង៖** ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

